ព្រះរាជក្រម

នស/រកម/១២០៧/០៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរារាម សម្ពរហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

លេខ... ថ្ងៃទី... ឆ្នាំ២០០៧ ម៉ោង... បញ្ជូនទៅ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
លេខ ...៦៣០
ថ្ងៃ ២៦.១២.០៧
បញ្ជូនទៅ ...

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងពិធីសារ សម្រាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភា ពុំអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
# ក្របខ័ណ្ឌ និងពិធីសារសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងពិធីសារសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដែលធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ និងនៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងពិធីសារនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នស.រកម.០៧១២.២២៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ៥៧៧ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០០៧

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

...ង សេនា និងបច្ចេកទេស
...ានស្រាវជ្រាវច្បាប់
... ៥៩៣ ...
...១១.០៧.០៨ ម៉ោង ...
...ទៅ ...

# កិច្ចព្រមព្រៀងក្របខ័ណ្ឌ
# ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ
# រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

<u>បុព្វកថា</u>

**យើង** ជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល នៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ("ឡាវ PDR") ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបូរី រាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា "អាស៊ាន" ឬ "រដ្ឋជាសមាជិកអាស៊ាន" ឬសមាជិកនីមួយៗ "រដ្ឋជាសមាជិកអាស៊ានមួយ") និងសាធារណរដ្ឋប្រជាមានិតចិន ( ហៅកាត់ថា "ចិន"):

**ដោយរំលឹកឡើងវិញ** នូវសេចក្តីសំរេចិត្តរបស់យើង នៅឯកិច្ចប្រជុំកំពូលអាស៊ាន-ចិន នៅថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០០១ នៅទីក្រុងបានដាសេរីបេហ្គាវ៉ាន ប្រទេសប្រ៊ុយណេដារូសាឡាំ ទាក់ទងទៅនឹងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ("អាស៊ាន-ចិន FTA") នៅក្នុងរង្វង់ដប់ឆ្នាំ ដោយផ្តល់នូវប្រព្រឹត្តិកម្មពិសេស និងផ្សេងៗគ្នា និងមានភាពទន់ភ្លន់ចំពោះរដ្ឋជាសមាជិកអាស៊ានថ្មី កម្ពុជា ឡាវ PDR មីយ៉ាន់ម៉ា និងវៀតណាម ("រដ្ឋជាសមាជិកអាស៊ានថ្មី") ដោយរួមទាំងបញ្ញត្តិសំរាប់ប្រមូលផលដើមដៃ ដែលក្នុងនោះ មានទាំងបញ្ជីមុខទំនិញ និងសេវាកម្មផ្សេងៗ ដែលនឹងត្រូវធ្វើសេចក្តីសំរេចចិត្ត តាមរយៈការពិគ្រោះយោបល់ទៅវិញទៅមក ។

**ដោយប្រាថ្នា** ធ្វើការអនុម័តនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ("កិច្ចព្រមព្រៀងនេះ") រវាងអាស៊ាន និងចិន (ហៅកាត់ថា "ភាគីទាំងអស់" ឬសមាជិកនីមួយៗ ដោយសំដៅទៅលើរដ្ឋជាសមាជិកអាស៊ានមួយ ឬចិន គឺជា "ភាគីមួយ") សម្លឹងឆ្ពោះទៅមុខ ដើម្បីបង្កើតទំនាក់ទំនងសេដ្ឋកិច្ចឱ្យកាន់តែជិតស្និទ្ធ នៅក្នុងសតវត្សទី២១ នេះ ។

**ដោយប្រាថ្នា** ធ្វើឱ្យរបាំងផ្សេងៗនៅជាអប្បរមា និងភ្ជាប់ចំណងសេដ្ឋកិច្ចរវាងភាគីទាំងអស់ ឱ្យកាន់តែជ្រាលជ្រៅ កាត់បន្ថយចំណាយឱ្យកាន់តែទាប បង្កើនពាណិជ្ជកម្ម និងវិនិយោគនៅក្នុងតំបន់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច បង្កើតនូវទីផ្សារមួយឱ្យកាន់តែទូលំទូលាយ ជាមួយនឹងឱកាសកាន់តែសំបូរបែប និងមាន ៧

សេដ្ឋកិច្ចមាត្រដ្ឋានកាន់តែធំ សំរាប់អាជីវកម្មរបស់ភាគីទាំងអស់ និងបង្កើនភាពទាក់ទាញរបស់ភាគីទាំងអស់ ដើម្បីស្រូបយកមូលធន និងជំនាញ ។

**ដោយមានជំនឿថា** ការបង្កើតឡើងនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងភាពជាដៃគូរវាង ភាគីទាំងអស់ នឹងផ្តល់នូវយន្តការដ៏សំខាន់មួយ សំរាប់ពង្រឹងកិច្ចសហប្រតិបត្តិការ និងទ្រទ្រង់ដល់ស្ថិរភាព សេដ្ឋកិច្ចនៅតំបន់អាស៊ីខាងកើត ។

**ដោយទទួលស្គាល់** នូវតួនាទី និងការចូលរួមវិភាគទានដ៏សំខាន់នៃវិស័យឯកជន នៅក្នុងការលើក ស្ទួយពាណិជ្ជកម្ម និងវិនិយោគ រវាងភាគីទាំងអស់ និងភាពចាំបាច់ដើម្បីជំរុញ និងសំរួលកិច្ចសហប្រតិបត្តិការ របស់ភាគីនានា និងការប្រើប្រាស់នូវឱកាសពាណិជ្ជកម្មដែលផ្តល់ដោយតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ឱ្យ បានកាន់តែខ្លាំងក្លាថែមទៀត ។

**ដោយទទួលស្គាល់** នូវជំហាននៃការលូតលាស់សេដ្ឋកិច្ចផ្សេងៗគ្នា នៅក្នុងចំណោមរដ្ឋជាសមាជិក អាស៊ាន និងតំរូវការចាំបាច់នៃភាពទន់ភ្លន់ ជាពិសេស តំរូវការចាំបាច់នៅក្នុងការសំរួល ដើម្បីបង្កើនការ ចូលរួមរបស់រដ្ឋជាសមាជិកអាស៊ានថ្មី ឱ្យបានកាន់តែប្រសើរថែមទៀត នៅក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាស៊ាន-ចិន និងពង្រីកការនាំចេញរបស់សមាជិកទាំងនេះ ដោយរួមទាំងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត តាមរយៈ ការជួយពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងក្នុងស្រុករបស់ពួកគេ ។

**ដោយអះអាងជាថ្មី** នូវសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវនៃភាគីនីមួយៗ នៅក្រោមអង្គការ ពាណិជ្ជកម្មពិភពលោក (WTO) និងនៅក្រោមកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី និងកិច្ចព្រមព្រៀង ផ្សេងៗទៀត ។

**ដោយទទួលស្គាល់** នូវតួនាទីជាកាតាលីករ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ ដែលអាច ចូលរួមវិភាគទានឆ្ពោះទៅធ្វើការពន្លឿនសេរីភាវូបនីយកម្មនៅក្នុងតំបន់ និងពិភពលោក ហើយវាជាបំណែក នៅក្នុងក្របខ័ណ្ឌ នៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី ។

**បានព្រមព្រៀងដូចខាងក្រោម៖**

## មាត្រា១

## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះដើម្បី:

(ក) ពង្រឹង និងលើកស្ទួយកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ រវាងភាគីទាំងអស់ ។ ៷

(ខ) បើកចំហ និងជំរុញពាណិជ្ជកម្មទំនិញ និងពាណិជ្ជកម្មសេវាកម្មឱ្យកាន់តែសេរី ព្រមទាំងបង្កើតរបប វិនិយោគមួយប្រកបដោយតម្លាភាព សេរី និងសមញ្ញ ។

(គ) រាវរកវិស័យថ្មីៗ និងបង្កើតវិធានការសមស្រប សំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែស្អិតស្អាលរវាងភាគីទាំងអស់ ។

(ឃ) សំរួលការធ្វើសមាហរ័ណកម្មសេដ្ឋកិច្ចរបស់សមាជិកអាស៊ានថ្មី ឱ្យកាន់តែមានប្រសិទ្ធភាព និងបង្រួមគម្លាតនៃការអភិវឌ្ឍន៍នៅក្នុងចំណោមភាគីទាំងអស់ ។

## មាត្រា២

## វិធានការសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ

ភាគីទាំងអស់ត្រូវព្រមព្រៀងគ្នាធ្វើការចរចាជាប្រញាប់ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នៅក្នុងរង្វង់១០ឆ្នាំ និងដើម្បីពង្រឹង និងលើកស្ទួយកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈវិធានការដូចខាងក្រោម៖

(ក) ធ្វើការលុបបំបាត់ពន្ធគយ និងរបាំងមិនមែនពន្ធគយជាជំហានៗ ឱ្យបានច្រើននៅក្នុងពាណិជ្ជកម្មទំនិញ ។

(ខ) ធ្វើសេរីភាវូបនីកម្មជាបណ្តើរៗទៅលើពាណិជ្ជកម្មសេវាកម្ម ដោយគ្របដណ្តប់ទៅលើវិស័យជាច្រើន ។

(គ) ធ្វើការបង្កើតឡើងនូវរបបវិនិយោគមួយប្រកបដោយសេរី និងប្រកួតប្រជែង ដែលនឹងជួយសំរួល និងជំរុញដល់ការវិនិយោគនៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ។

(ឃ) បង្កើតបញ្ញត្តិស្តីពីប្រព្រឹត្តិកម្មពិសេស និងផ្សេងៗគ្នា និងភាពទន់ភ្លន់ ចំពោះរដ្ឋជាសមាជិកអាស៊ានថ្មី ។

(ង) បង្កើតបញ្ញត្តិ ស្តីពីភាពទន់ភ្លន់សំរាប់ភាគីទាំងអស់ នៅក្នុងការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដើម្បីដោះស្រាយនូវបញ្ហារសេយិតភាពរបស់ពួកគេ នៅក្នុងផ្នែកពាណិជ្ជកម្មទំនិញ សេវាកម្ម និងវិនិយោគ តាមរយៈការចរចា និងស្រុះស្រួលគ្នា ដោយឈរនៅលើគោលការណ៍ទទួលបានផលប្រយោជន៍ទៅវិញទៅមក ។៧

(ច) បង្កើតឡើងនូវវិធានការសំរួលពាណិជ្ជកម្ម និងវិនិយោគ ប្រកបដោយប្រសិទ្ធភាពនានា ដោយរួមបញ្ចូល ប៉ុន្តែមិនបានកំរិត ចំពោះការធ្វើឱ្យមានភាពងាយស្រួលផ្នែកនីតិវិធីគយ និងការអភិវឌ្ឍន៍នូវកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក ។

(ឆ) ធ្វើការពង្រីកនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងវិស័យនានា ដែលអាចស្រុះស្រួលគ្នាទៅវិញទៅមករវាងភាគីទាំងអស់ ដែលនឹងបំពេញបន្ថែមលើជំរៅនៃការតភ្ជាប់ពាណិជ្ជកម្ម និងវិនិយោគ រវាងភាគីទាំងអស់ និងបង្កើតឡើងនូវផែនការសកម្មភាព និងកម្មវិធីផ្សេងៗ ដើម្បីធ្វើការអនុវត្តន៍លើផ្នែក/វិស័យនៃកិច្ចសហប្រតិបត្តិការនានា ដែលបានព្រមព្រៀងទាំងនោះ ។

(ជ) ធ្វើការបង្កើតឡើងនូវយន្តការដ៏សមស្របនានា ក្នុងបំណងដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ផ្នែកទី១

## មាត្រា៣

## ពាណិជ្ជកម្មផ្នែកទំនិញ

១. បន្ថែមទៅលើកម្មវិធីប្រមូលផលដើមដៃ នៅក្រោមមាត្រា៦ នៃកិច្ចព្រមព្រៀងនេះ និងក្នុងគោលបំណងដើម្បីពង្រីកពាណិជ្ជកម្មផ្នែកទំនិញឱ្យបានរួសរាន់ ភាគីទាំងអស់ព្រមព្រៀងគ្នាចាប់ ផ្តើមបើកការចរចា ដែលនៅក្នុងនោះមាន ការចរចាលើផ្នែកពន្ធគយ និងលើបទបញ្ញត្តិនៃការរឹតត្បិតទៅលើពាណិជ្ជកម្មនានា (លើកលែងតែបញ្ហាចាំបាច់មួយចំនួន ដែលបញ្ហាទាំងនោះ ស្ថិតនៅក្រោមមាត្រា XXIV (៨) (ខ) នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) របស់អង្គការ WTO ដែលត្រូវបានអនុញ្ញាត) ដែលបទបញ្ញត្តិ និងវិធានការទាំងនោះ នឹងត្រូវបានគេលុបចោលភាគច្រើននៅក្នុងពាណិជ្ជកម្មទំនិញ រវាងភាគីទាំងអស់ ។

២. ចំពោះគោលបំណងនៃមាត្រានេះ និយមន័យខាងក្រោមត្រូវអនុវត្តបាន បើពុំមានបរិបទណាតំរូវឱ្យផ្ទុយពីនេះ:

(ក) “ASEAN 6” សំដៅទៅលើប្រទេស ប្រ៊ុយណេដារូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៍ ។

(ខ) “អត្រាពន្ធគយអនុវត្ត MFN ” ត្រូវរាប់បញ្ចូលទាំងអត្រាក្នុងកូតា និងត្រូវ : ✓

(១) ក្នុងករណីរដ្ឋជាសមាជិកអាស៊ាន (ដែលជាសមាជិកនៃអង្គការ WTO ចាប់តាំងពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣) និងប្រទេសចិន ត្រូវយោងទៅ លើអត្រាអនុវត្តរបស់រដ្ឋជាសមាជិកនីមួយៗ ចាប់ពីថ្ងៃ ទី១ ខែកក្កដា ឆ្នាំ២០០៣។

(២) ក្នុងករណីរដ្ឋជាសមាជិកអាស៊ាន (ដែលមិនមែនជាសមាជិកនៃអង្គការ WTO ចាប់ពី ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣) ត្រូវយោងទៅលើអត្រាដូចដែលបានអនុវត្តជាមួយប្រទេសចិន ចាប់ពីថ្ងៃទី១ ខែ កក្កដា ឆ្នាំ២០០៣)។

(គ) "វិធានការមិនមែនពន្ធគយ" ត្រូវរាប់បញ្ចូលទាំងរបាំងមិនមែនពន្ធគយផងដែរ ។

៣. កម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយរបស់ភាគីទាំងអស់ ត្រូវទាមទារឱ្យធ្វើការកាត់បន្ថយ និងលុបបំបាត់ជាបន្តបន្ទាប់នូវពន្ធគយលើផលិតផលដែលបានចុះបញ្ជី នៅពេលដែលអាចធ្វើទៅបាន ដោយស្របទៅតាមមាត្រានេះ។

៤. ផលិតផលដែលត្រូវបញ្ចូលទៅក្នុងកម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ នៅក្រោមមាត្រានេះត្រូវរួមបញ្ចូលនូវផលិតផលទាំងអស់ ដែលមិនគ្របដណ្ដប់ដោយកម្មវិធីប្រមូលផលដើមដៃ នៅក្រោមមាត្រាទី៦ នៃកិច្ចព្រមព្រៀងនេះ ហើយផលិតផលបែបនេះ ត្រូវចាត់បញ្ចូលនៅក្នុងកម្មវិធីពីរដូចខាងក្រោម:

**(ក) កម្មវិធីធម្មតា:** ផលិតផលដែលបានចុះបញ្ជីនៅក្នុងកម្មវិធីធម្មតា ដោយភាគីមួយ ដោយខ្លួនឯងត្រូវ:

**(១)** មានអត្រាពន្ធគយអនុវត្ត MFN ដែលត្រូវកាត់បន្ថយ ឬលុបបំបាត់ជាបន្តបន្ទាប់រៀងៗខ្លួន ស្របជាមួយនឹងកម្មវិធី និងអត្រាជាក់លាក់ (នឹងត្រូវមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីទាំងអស់) នៅលើរយៈពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ដល់២០១០ សំរាប់អាស៊ាន៦ និងប្រទេសចិន ហើយនៅក្នុងករណីរដ្ឋជាសមាជិកអាស៊ានថ្មី លើរយៈពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ដល់ ២០១៥ ដោយចាប់ផ្ដើមកាត់ពីអត្រាខ្ពស់ និងមានដំណាក់កាលផ្សេងៗគ្នា។

**(២)** ចំពោះពន្ធគយដែលត្រូវបានកាត់បន្ថយ ប៉ុន្តែមិនទាន់បានលុបបំបាត់ នៅក្រោមកថាខ័ណ្ឌ ៤ (ក)(១) ខាងលើ នឹងត្រូវបានលុបបំបាត់ជាបន្តបន្ទាប់ នៅក្នុងរយៈពេលកំណត់ ដែលបានព្រមព្រៀងរវាងភាគីទាំងអស់។

**(ខ) កម្មវិធីរសើប:** ផលិតផលដែលបានចុះបញ្ជីនៅក្នុងកម្មវិធីរសើប ដែលធ្វើឡើងដោយភាគីនីមួយៗ ដោយខ្លួនឯងត្រូវ: w

(១) មានអត្រាពន្ធគយអនុវត្ត MFN ដែលត្រូវកាត់បន្ថយ យោងទៅតាមការព្រមព្រៀងគ្នាលើអត្រា និងកាលបរិច្ឆេទចុងក្រោយ ។

(២) មានអត្រាពន្ធគយអនុវត្ត MFN ដែលត្រូវលុបបំបាត់ជាបន្តបន្ទាប់រៀងៗខ្លួន នៅពេលដែលអនុវត្តទៅបាន នៅក្នុងរយៈពេលកំណត់ដែលបានព្រមព្រៀងរវាងភាគីទាំងអស់ ។

៥. ចំនួនផលិតផលដែលបានចុះបញ្ជីនៅក្នុងកម្មវិធីវេទយិត ត្រូវមានកំរិតអតិបរមាដែលបានព្រមព្រៀងរវាងភាគីទាំងអស់ ។

៦. ការសន្យាដែលបានធ្វើដោយភាគីទាំងអស់នៅក្រោមមាត្រានេះ និងមាត្រា៦ នៃកិច្ចព្រមព្រៀងនេះ ត្រូវបំពេញនូវតំរូវការរបស់អង្គការ WTO ដោយធ្វើការលុបបំបាត់ពន្ធគយឱ្យបានច្រើនលើពាណិជ្ជកម្មរវាងភាគីទាំងអស់ ។

៧. អត្រាពន្ធគយជាក់លាក់ ដែលបានព្រមព្រៀងទៅវិញទៅមករវាងភាគីទាំងអស់ ស្របតាមមាត្រានេះ ត្រូវកំណត់ត្រឹមតែចំនួនកំរិតនៃអត្រាពន្ធគយដែលអាចអនុវត្តទៅបាន ឬកំណត់ចំនួនឆ្នាំជាក់លាក់នៃការអនុវត្តដោយភាគីទាំងអស់ និងមិនរារាំងភាគីណាមួយពីការពន្លឿននៃការកាត់បន្ថយ ឬលុបបំបាត់ពន្ធគយរបស់គេឡើយ ប្រសិនបើគេប្រាថ្នាធ្វើដូច្នេះ ។

៨. ការចរចាររវាងភាគីទាំងអស់ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដោយគ្របដណ្តប់ទៅលើពាណិជ្ជកម្មទំនិញ នឹងត្រូវរាប់បញ្ចូល ប៉ុន្តែមិនត្រូវបានកំរិត ចំពោះបញ្ហាខាងក្រោមៈ

(ក) បញ្ញត្តិពិស្តារផ្សេងៗ ដែលក្តោបទៅលើកម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ សំរាប់កម្មវិធីធម្មតានិងកម្មវិធីវេទយិត ព្រមទាំងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត រួមទាំងគោលការណ៍នានាដែលក្តោបទៅលើការសន្យាមានទៅមានមក ដែលមិនមានចែងនៅក្នុងកថាខ័ណ្ឌមុនៗ នៃមាត្រានេះផងដែរ ។

(ខ) វិធានប្រភពដើមទំនិញ

(គ) ប្រព្រឹត្តិកម្មក្រៅកូតា

(ឃ) ការកែប្រែនៃការសន្យារបស់ភាគីមួយ នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ត្រូវផ្អែកលើមាត្រា XXVIII របស់ GATT ។

(ង) វិធានការមិនមែនពន្ធគយ ដែលបានដាក់ទៅលើផលិតផលមួយចំនួន គ្របដណ្តប់នៅក្រោមមាត្រានេះ ឬមាត្រា៦ នៃកិច្ចព្រមព្រៀងនេះ បានរួមបញ្ចូល ប៉ុន្តែមិនបានកំរិតចំពោះការរឹតត្បិតលើបរិមាណ ឬការហាមឃាត់លើការនាំចូលនៃផលិតផលណាមួយ ឬលើការនាំ៚

ចេញ ឬលក់សំរាប់នាំចេញនៃផលិតផលណាមួយ ព្រមទាំងវិធានការអនាម័យនិងភូតគាមអនាម័យបែបវិទ្យាសាស្ត្រដោយគ្មានសច្ចភាព និងរបាំងបច្ចេកទេសពាណិជ្ជកម្ម ។

(ច) ការការពារទាំងឡាយដែលផ្អែកលើគោលការណ៍ GATT រួមបញ្ចូល ប៉ុន្តែមិនបានកំរិតចំពោះកត្តាជាបន្តបន្ទាប់នេះ: តម្លាភាព ទំហំ លក្ខណៈវិនិច្ឆ័យកម្មវត្ថុសំរាប់ធ្វើសកម្មភាព រួមទាំងគោលគំនិតនៃការខូចខាតធ្ងន់ធ្ងរ ឬការគំរាមកំហែង និងធម្មជាតិមិនឋិតថេរផងដែរ ។

(ឆ) បទបញ្ញត្តិស្តីពីវិធានការឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ និងវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ដោយផ្អែកលើបទវិន័យទាំងឡាយរបស់ GATT ។

(ជ) ការសំរួល និងការជំរុញការការពារឱ្យបានគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពនៃពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដោយផ្អែកលើបទបញ្ញត្តិដែលមានស្រាប់របស់អង្គការ WTO អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) និងបទវិន័យពាក់ព័ន្ធផ្សេងៗទៀត ។

## មាត្រា៤
## ពាណិជ្ជកម្មសេវាកម្ម

ក្នុងគោលបំណងដើម្បីពង្រីកពាណិជ្ជកម្មសេវាកម្មឱ្យបានរូសរាន់ ភាគីទាំងអស់ធ្វើការព្រមព្រៀងគ្នា ចាប់ផ្តើមចរចាធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម ឱ្យកាន់តែប្រសើរ ដោយគ្របដណ្តប់ទៅលើវិស័យជាច្រើន។ ការចរចាបែបនេះ នឹងផ្តោះទៅ:

(ក) លុបបំបាត់ចោលជាបណ្តើរៗ នូវការរើសអើងគ្រប់ប្រភេទ រវាង ឬក្នុងចំណោមភាគីទាំងអស់ និង / ឬ ហាមឃាត់ នូវការដាក់វិធានការរើសអើងថ្មីៗ ឬច្រើនទៀត ទៅលើពាណិជ្ជកម្មសេវាកម្ម លើកលែងតែវិធានការទាំងនោះស្ថិតនៅក្រោមមាត្រា ៥ (១)(ខ) នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) របស់អង្គការ WTO ដែលត្រូវបានអនុញ្ញាត ។

(ខ) ពង្រីកការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មឱ្យកាន់តែជ្រាលជ្រៅ និងទូលំទូលាយជាងការធ្វើសេរីនីយកម្មរបស់រដ្ឋជាសមាជិកអាស៊ាន និងចិននៅក្រោម GATS ។

(គ) លើកកំពស់នូវកិច្ចសហប្រតិបត្តិការលើវិស័យសេវាកម្ម រវាងភាគីទាំងអស់ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពប្រកួតប្រជែង ព្រមទាំងពង្រីកការផ្គត់ផ្គង់ និងចែកចាយសេវារបស់អ្នកផ្តល់សេវាកម្មនៃភាគីទាំងអស់ ។

## មាត្រា៥
## វិនិយោគ

ដើម្បីជំរុញ និងបង្កើតរបបវិនិយោគមួយឱ្យកាន់តែសេរី ងាយស្រួល មានតម្លាភាព និងមានភាពប្រកួតប្រជែង ភាគីទាំងអស់ត្រូវព្រមព្រៀងគ្នា:

(ក) ធ្វើការចរចារ ដើម្បីបើកចំហរបបវិនិយោគទុនឱ្យកាន់តែប្រសើរឡើង ។

(ខ) ធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកវិនិយោគ សំរួលការវិនិយោគ និងបង្កើនតម្លាភាពផ្នែកច្បាប់ និងបទវិន័យលើការវិនិយោគ ។

(គ) ផ្តល់នូវការការពារលើវិនិយោគ ។

## មាត្រា៦
## ការប្រមូលផលដើមដៃ

១. ក្នុងគោលបំណងដើម្បីបង្កើនការអនុវត្តន៍នូវកិច្ចព្រមព្រៀងនេះ ភាគីទាំងអស់ព្រមព្រៀងគ្នាធ្វើការអនុវត្តន៍កម្មវិធីប្រមូលផលដើមដៃ (ដែលជាផ្នែកមួយដ៏សំខាន់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន)សំរាប់ផលិតផលដែលគ្របដណ្តប់នៅក្រោមកថាខ័ណ្ឌ ៣ (ក) ខាងក្រោម ហើយដែលនឹងចាប់ផ្តើម និងបញ្ចប់អនុលោមទៅតាមក្របខ័ណ្ឌពេលវេលា ដែលបានចែងក្នុងមាត្រានេះ ។

២. ចំពោះគោលបំណងនៃមាត្រានេះ និយមន័យខាងក្រោមត្រូវអនុវត្តបាន បើពុំមានបរិបទណាតំរូវឱ្យផ្ទុយពីនេះ:

ក. អាស៊ាន៦ គឺសំដៅលើ ប្រទេសប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបូរី និង ថៃឡង់ដ៍ ។

ខ. អត្រាពន្ធគយអនុវត្ត MFN ត្រូវរួមបញ្ចូលទាំងអត្រាពន្ធក្នុងកូតា និងត្រូវ: ៧

១.	ក្នុងករណីសមាជិកអាស៊ាន (ដែលជាសមាជិកអង្គការ WTO ត្រូវអនុវត្តគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៣) និងប្រទេសចិន ត្រូវយោងទៅលើអត្រាពន្ធគយអនុវត្ត គិតចាប់ពីថ្ងៃទី១ ខែ មករា ឆ្នាំ២០០៣ ។

២.	ក្នុងករណីសមាជិកអាស៊ាន (ដែលមិនមែនជាសមាជិកអង្គការ WTO ត្រូវអនុវត្តគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៣) ដោយយោងទៅលើអត្រាពន្ធគយ ដែលអនុវត្តចំពោះប្រទេសចិន គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៣។

៣.	ទំហំផលិតផល ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ ការអនុវត្តន៍ទៅតាមក្របខ័ណ្ឌពេលវេលា វិធានប្រភពដើមទំនិញ សំណងទូទាត់ពាណិជ្ជកម្ម និងវិធានការការពារបន្ទាន់ ដែលអាចអនុវត្តចំពោះកម្មវិធីប្រមូលផលដើមដៃ រួមមានដូចខាងក្រោម :

**(ក) ទំហំផលិតផល**

១.	ផលិតផលទាំងអស់ ដែលស្ថិតនៅក្នុងជំពូកបន្តបន្ទាប់ដែលមានលេខសំគាល់ប្រព័ន្ធស្របគ្នាពីលេខ៨-៩ ខ្ទង់ (8/9 digit level "HS Code") ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីប្រមូលផលដើមដៃ បើមិនដូច្នោះទេ លុះណាតែ ត្រូវដកចេញដោយភាគីណាមួយពីក្នុងបញ្ជីលើកលែងរបស់ខ្លួន ដូចដែលបានចែងក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនេះ ដែលក្នុងករណីនេះ ផលិតផលទាំងនេះ ត្រូវបានលើកលែងចំពោះភាគីនោះ:

| **ជំពូក** | **ការបរិយាយមុខទំនិញ** |
|---|---|
| ០១ | សត្វរស់ |
| ០២ | សាច់ និងកំទេចសាច់សេសសល់ដែលអាចបរិភោគបាន |
| ០៣ | ត្រី |
| ០៤ | ផលិតផលប្រើប្រាស់ប្រចាំថ្ងៃ |
| ០៥ | ផលិតផលដែលផលិតចេញពីសត្វដទៃទៀត |
| ០៦ | រុក្ខជាតិមានជីវិត |
| ០៧ | បន្លែដែលអាចបរិភោគបាន |
| ០៨ | ផ្លែឈើ និងដំណាប់ដែលអាចបរិភោគបាន |

២.	ភាគីមួយដែលដាក់បញ្ចូលផលិតផលទៅក្នុងបញ្ជីលើកលែង អាចធ្វើការកែប្រែបញ្ជីលើកលែងនោះបាននៅពេលណាមួយ ដើម្បីដាក់ផលិតផលមួយ ឬច្រើនមុខក្នុងចំណោមផលិតផលទាំងនោះ ឱ្យស្ថិតនៅក្រោមកម្មវិធីប្រមូលផលដើមដៃ។

៣.	ផលិតផលជាក់លាក់ផ្សេងៗ ដែលមានចែងក្នុងឧបសម្ព័ន្ធទី២ នៃកិច្ចព្រមព្រៀងនេះ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីប្រមូលផលដើមដៃ ហើយសម្បទានពន្ធគយ ត្រូវអនុវត្តទៅលើតែភាគីដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី២។ ភាគីទាំងនោះ ត្រូវតែផ្តល់សម្បទានពន្ធគយ លើផលិតផលទាំងនោះ អោយគ្នាទៅវិញទៅមក។

៤.	ចំពោះភាគី ដែលមិនអាចបញ្ចប់បញ្ជីផលិតផលសមស្របនៅក្នុងឧបសម្ព័ន្ធ១ ឬឧបសម្ព័ន្ធ២ បញ្ជីទាំងនោះនៅតែអាចត្រូវបន្តធ្វើបាន ដោយមិនអោយហួសពីថ្ងៃទី១ ខែមិនា ឆ្នាំ២០០៣ ដោយការព្រមព្រៀងទៅវិញទៅមក។

**(ខ)	ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ**

១.	ផលិតផលទាំងអស់ដែលស្ថិតក្រោមកម្មវិធីប្រមូលផលដើមដៃ ត្រូវចែកចេញជាផលិតផល ៣ ប្រភេទ សំរាប់ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ ដូចដែលបានកំណត់ និងត្រូវអនុវត្តដោយអនុលោមទៅតាមក្របខ័ណ្ឌពេលវេលា ដែលបានចែងក្នុងឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀងនេះ។ បទបញ្ញត្តិនេះ នឹងមិនហាមឃាត់ភាគីណាមួយពីការបង្កើនល្បឿនដើម្បីកាត់បន្ថយនិងលុបបំបាត់ពន្ធគយទេ ប្រសិនបើភាគីនោះមានបំណងចង់ធ្វើដូច្នេះ។

២.	ផលិតផលទាំងអស់ ដែលអត្រាពន្ធគយអនុវត្ត MFN មានកំរិត 0% ត្រូវតែរក្សា 0% ដដែល។

៣.	អត្រាពន្ធគយដែលត្រូវកាត់បន្ថយឱ្យនៅ 0% ត្រូវតែរក្សានៅ 0% ដដែល។

៤.	ភាគីមួយ ត្រូវទទួលបានសម្បទានពន្ធគយពីភាគីដទៃទៀត ចំពោះផលិតផលក្រោមកថាខ័ណ្ឌ ៣ (ក)(១) ខាងលើ ឱ្យតែផលិតផលដូចគ្នារបស់ភាគីនោះ ស្ថិតក្រោមកម្មវិធីប្រមូលផលដើមដៃ នៅក្រោមកថាខ័ណ្ឌ ៣ (ក)(១)។ល

(ឥ) **វិធានប្រភពដើមបណ្តោះអាសន្ន**

វិធានប្រភពដើមបណ្តោះអាសន្ន អាចអនុវត្តបានទៅលើផលិតផលទាំងឡាយ ដែលគ្របដណ្តប់នៅក្រោមកម្មវិធីប្រមូលផលដើមដៃ ដែលត្រូវតែចរចា និងសំរេចឱ្យបាននៅត្រឹមខែកក្កដា ឆ្នាំ ២០០៣។ វិធានប្រភពដើមបណ្តោះអាសន្ន នឹងត្រូវបានច្រានចោល និងជំនួសមកវិញដោយវិធានប្រភពដើមទំនិញ ដែលត្រូវបានចរចា និងអនុវត្តដោយភាគីទាំងអស់ក្រោមមាត្រា ៣ (៨)(ខ) នៃកិច្ចព្រមព្រៀងនេះ។

(ឈ) **ការអនុវត្តន៍បទបញ្ញត្តិរបស់អង្គការ WTO**

បទបញ្ញត្តិរបស់អង្គការ WTO ដែលគ្រប់គ្រងទៅលើការកែប្រែនៃការសន្យា សកម្មភាពការពារ វិធានការការពារបន្ទាន់ និងរាល់សំណងទូទាត់ពាណិជ្ជកម្មផ្សេងៗទៀត ដែលរួមមាន វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ នៅក្នុងរយៈពេលបណ្តោះអាសន្ន ត្រូវអាចអនុវត្តបានចំពោះផលិតផលទាំងអស់ ដែលគ្របដណ្តប់ក្រោមកម្មវិធីប្រមូលផលដើមដៃ ដែលនឹងត្រូវបានច្រានចោល និងជំនួសមកវិញនូវបទវិន័យពាក់ព័ន្ធ ផ្សេងៗ ដែលត្រូវបានចរចា និងព្រមព្រៀងដោយភាគីទាំងអស់ក្រោមមាត្រា ៣ (៨) នៃ កិច្ចព្រមព្រៀងនេះ នៅពេលបទវិន័យទាំងនេះចូលជាធរមាន។

៤. ដោយបន្ថែមទៅលើកម្មវិធីប្រមូលផលដើមដៃ សំរាប់ពាណិជ្ជកម្មទំនិញ ដូចដែលបានចែងនៅក្នុងកថាខ័ណ្ឌខាងដើមនៃមាត្រានេះ ភាគីទាំងអស់ នឹងស្វែងរកអោយឃើញពីភាពដែលអាចធ្វើទៅបាននៃកម្មវិធីប្រមូលផលដើមដៃ សំរាប់ពាណិជ្ជកម្មសេវាកម្មនៅដើមឆ្នាំ២០០៣។

៥ ក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងភាគីទាំងអស់ សកម្មភាពដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី៤ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវប្រកាន់យក ឬអនុវត្ត ឈរលើមូលដ្ឋានពន្លឿនមួយ ជាករណីដែលអាចធ្វើទៅបាន។

## ផ្នែកទី២

## មាត្រា៧

## កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចលើវិស័យផ្សេងៗទៀត

១. ភាគីទាំងអស់ព្រមព្រៀងគ្នា ធ្វើការពង្រឹងនូវកិច្ចសហប្រតិបត្តិការរបស់ខ្លួន នៅលើលើវិស័យអាទិភាពចំនួន៥ ដូចខាងក្រោម:

(ក) កសិកម្ម

(ខ) ពត៌មាន និងបច្ចេកវិទ្យាគមនាគមន៍

(គ) ការអភិវឌ្ឍន៍ធនធានមនុស្ស

(ឃ) ការវិនិយោគ

(ង) ការអភិវឌ្ឍន៍អាងទន្លេមេគង្គ

២. កិច្ចសហប្រតិបត្តិការត្រូវគ្របដណ្តប់ទៅលើវិស័យផ្សេង១ ដោយរាប់បញ្ចូល ប៉ុន្តែមិនបានកំរិតចំពោះ វិស័យធនាគារ ហិរញ្ញវត្ថុ ទេសចរណ៍ ឧស្សាហកម្ម ដឹកជញ្ជូន ទូរគមនាគមន៍ កម្មសិទ្ធបញ្ញា សហគ្រាសធុនតូចនិងមធ្យម (SMEs) បរិស្ថាន ជីវបច្ចេកវិទ្យា នេសាទ រុក្ខា និងរុក្ខផល រ៉ែ ថាមពល និងការអភិវឌ្ឍន៍អនុតំបន់។

៣. វិធានការដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ នឹងរួមបញ្ចូល ប៉ុន្តែមិនបានកំរិត ចំពោះ:

ក. ការជំរុញ និងការសំរបសំរួលពាណិជ្ជកម្មទំនិញ និងសេវាកម្ម និងការវិនិយោគ ដូចជា:

១. ស្តង់ដារ និងការវាយតំលៃស្របគ្នា

២. របាំងបច្ចេកទេសពាណិជ្ជកម្ម ឬវិធានការមិនមែនពន្ធគយ

៣. កិច្ចសហប្រតិបត្តិការផ្នែកគយ

ខ. ការបង្កើននូវភាពប្រកួតប្រជែងលើវិស័យ SMEs

គ. ការជំរុញពាណិជ្ជកម្មតាមរយៈអេឡិចត្រូនិច

ឃ. ការកសាងសមត្ថភាព

ង. ការផ្ទេរបច្ចេកវិទ្យា

៤. ភាគីទាំងអស់យល់ព្រមអនុវត្តកម្មវិធីកសាងសមត្ថភាពនានា និងជំនួយបច្ចេកទេស ជាពិសេសសំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី ដើម្បីកែសំរួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និងពង្រីកពាណិជ្ជកម្ម និងវិនិយោគរបស់ពួកគេ។

## ផ្នែកទី៣

## មាត្រា៨

## ក្របខ័ណ្ឌពេលវេលា

១.	ចំពោះពាណិជ្ជកម្មទំនិញ ការចរចាលើកិច្ចព្រមព្រៀង ដើម្បីការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ និងបញ្ហាដទៃៗ ទៀត ដូចមានចែងនៅក្នុងមាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ នឹងចាប់ផ្តើមនៅដើមឆ្នាំ ២០០៣ ហើយត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន ដែលគ្របដណ្តប់លើពាណិជ្ជកម្មទំនិញនៅឆ្នាំ ២០១០ សំរាប់ប្រទេសប្រ៊ុយណេ ចិន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃឡង់ដ៏ និងនៅឆ្នាំ ២០១៥ សំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី។

២.	ការចរចាអំពីវិធានប្រភពដើមទំនិញ សំរាប់ពាណិជ្ជកម្មទំនិញនៅក្រោមមាត្រា៣ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបញ្ចប់មិនអោយយឺតជាងខែធ្នូ ឆ្នាំ២០០៣។

៣.	ចំពោះពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ ការចរចាលើកិច្ចព្រមព្រៀងនីមួយៗ នឹងចាប់ផ្តើមនៅឆ្នាំ ២០០៣ ហើយត្រូវបញ្ចប់ដោយឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើការអនុវត្តន៍ឱ្យស្របតាមក្របខ័ណ្ឌពេលវេលា ដែលនឹងត្រូវបានឯកភាពគ្នាទៅវិញទៅមក: (ក) ធ្វើការការពិចារណាលើផ្នែកវេទយិតនានារបស់ភាគីទាំងអស់ និង (ខ) ផ្តល់នូវប្រព្រឹត្តិកម្មពិសេស និងដោយឡែក និងភាពទន់ភ្លន់ចំពោះរដ្ឋជាសមាជិកអាស៊ានថ្មី។

៤.	ចំពោះវិស័យសហប្រតិបត្តិការសេដ្ឋកិច្ចផ្សេងៗទៀត ក្នុងផ្នែកទី២ នៃកិច្ចព្រមព្រៀងនេះ ភាគីទាំងអស់នឹងបន្តការកសាងលើកម្មវិធីដែលមានស្រាប់ ឬកម្មវិធីដែលបានព្រមព្រៀងគ្នា ដូចមានចែងក្នុងមាត្រា៧ នៃកិច្ចព្រមព្រៀងនេះ និងធ្វើការអភិវឌ្ឍន៍នូវកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចថ្មីៗ និងបញ្ចប់កិច្ចប្រមព្រៀងនានា នៅលើវិសយ័សហប្រតិបត្តិការសេដ្ឋកិច្ចផ្សេងៗទៀត។ ភាគីទាំងអស់ត្រូវធ្វើដោយរូសរាន់ដូច្នេះ ដើម្បីចាប់ផ្តើមអនុវត្តន៍នៅក្នុងសភាពដំបូង និងនៅក្នុងដំណាក់កាលមួយដែលអាចទទួលធ្វើបាន ដោយភាគីពាក់ព័ន្ធទាំងអស់។ កិច្ចព្រមព្រៀងទាំងនេះ នឹងរួមបញ្ចូលនៅក្នុងនោះនូវក្របខ័ណ្ឌពេលវេលាសំរាប់ធ្វើការអនុវត្តន៍នៃការសន្យាផងដែរ។

## មាត្រា៩

## ប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត

ប្រទេសចិន នឹងយល់ព្រមផ្តល់នូវប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត ដែលស្របទៅនឹងច្បាប់ និងបទវិន័យរបស់អង្គការ WTO ដល់រដ្ឋជាសមាជិកអាស៊ានទាំងអស់ ដែលមិនមែនជាសមាជិករបស់អង្គការ WTO ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះតទៅ។

## មាត្រា១០

## ការលើកលែងទូទៅ

ដោយផ្អែកទៅលើតំរូវការ វិធានការបែបនេះ មិនត្រូវបានអនុវត្តនៅក្នុងសភាពដែលអាចបង្កើតជាមធ្យោ-បាយរំលោភបំពាន ឬការរើសអើយដោយអយុត្តិធម៌រវាង ឬក្នុងចំណោមភាគីទាំងអស់ ដែលស្ថិតនៅក្នុងលក្ខខ័ណ្ឌដូចគ្នា ឬធ្វើការរិតត្បិតលើពាណិជ្ជកម្មដោយលាក់កំបាំង នៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន នោះទេ ហើយគ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងហាមឃាត់ភាគីណាមួយពីការអនុម័ត និងចាត់វិធានការទាំងឡាយ ដើម្បីការពារសន្តិសុខជាតិ ឬការពារតំលៃខាងសិល្បៈ ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា របស់ខ្លួន ឬវិធានការផ្សេងៗទៀតដែលចាត់ទុកថា ជាការចាំបាច់សំរាប់ការការពារសីលធម៌សាធារណៈ ឬសំរាប់ការពារមនុស្ស សត្វ ឬជីវិតរុក្ខជាតិ និងសុខភាពនោះឡើយ ។

## មាត្រា១១

## យន្តការដោះស្រាយវិវាទ

១. រយៈពេល១ឆ្នាំក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីទាំងអស់ត្រូវបង្កើតឡើងនូវយន្តការ និងនិតិវិធីដោះស្រាយវិវាទជាផ្លូវការសមស្របមួយ ដើម្បីបំពេញបានតាមគោលបំណងនៃកិច្ចព្រម-ព្រៀងនេះ ។

២. នៅក្នុងកំឡុងនៃការរង់ចាំការបង្កើតយន្តការ និងនីតិវិធីដោះស្រាយវិវាទជាផ្លូវការ នៅក្រោមកថាខ័ណ្ឌទី១ខាងលើ រាល់វិវាទទាំងអស់ដែលពាក់ព័ន្ធនៅនឹងការអធិប្បាយ ការធ្វើ ឬកាអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានដោះស្រាយដោយមិត្តភាព តាមរយៈការពិគ្រោះយោបល់ និង/ឬការសំរុះសំរួលគ្នា ។

## មាត្រា១២

## ការរៀបចំស្ថាប័នចរចា

១. គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ចិន ( អាស៊ាន-ចិន NTC) ដែលត្រូវបានបង្កើតឡើងរួចមកហើយនោះ នឹងបន្តអនុវត្តកម្មវិធីចរចាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

២. ភាគីទាំងអស់អាចបង្កើតក្រុមការងារផ្សេងៗទៀត ព្រោះអាចជាការចាំបាច់សំរាប់ជួយសំរបសំរួល និងអនុវត្តសកម្មភាពសហប្រតិបត្តិការផ្សេងៗ នៅក្រោមកិច្ចព្រមព្រៀងនេះ ។

៣.	គណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ចិន និងក្រុមការងារដូចបានថ្លែងរួចមកហើយនោះ នឹងត្រូវរាយការណ៍អំពីភាពជឿនលឿន និងលទ្ធផលនៃកិច្ចចរចានានារបស់ខ្លួនជាប្រចាំ ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេស និងសហប្រតិបត្តិការសេដ្ឋកិច្ចចិន (MOFTEC) តាមរយៈកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន (SEOM) និង MOFTEC ។

៤.	លេខាធិការដ្ឋានអាស៊ាន និង MOFTEC ត្រូវរួមគ្នាជួយឧបត្ថម្ភជាលេខាធិការដ្ឋានចាំបាច់មួយ ដល់គណៈកម្មាធិការចរចារពាណិជ្ជកម្មអាស៊ាន-ចិន នៅពេលណា និងទីកន្លែងណាដែលមានបើកកិច្ចចរចា ។

## មាត្រា១៣

## បញ្ញត្តិផ្សេងៗ

១.	កិច្ចព្រមព្រៀងនេះ នឹងបញ្ចូលនូវឧបសម្ព័ន្ធ និងខ្លឹមសារនៅក្នុងនោះដែរ ហើយលិខិតុបករណ៍ច្បាប់អនាគតទាំងឡាយដែលបានព្រមព្រៀងគ្នា ត្រូវអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ ។

២.	លុះណាតែមានការចែងផ្ទុយពីកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះ ឬការចាត់វិធានការណាមួយនៅក្រោមកិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ ឬធ្វើឱ្យសិទ្ធិ និងកាតព្វកិច្ចនៃភាគីមួយទៅជាមោឃៈ នៅក្រោម កិច្ចព្រមព្រៀងដទៃៗទៀត ដែលគេមានស្រាប់នោះឡើយ ។

៣.	ភាគីទាំងអស់ ត្រូវខិតខំទប់ស្កាត់ការកើនឡើងនូវការរិតត្បិត ឬការកំរិត ដែលនឹងប៉ះពាល់ដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

## មាត្រា១៤

## វិសោធនកម្ម

បទបញ្ញត្តិទាំងឡាយ នៃកិច្ចព្រមព្រៀងនេះ អាចត្រូវបានកែប្រែ តាមរយៈការធ្វើវិសោធនកម្ម ដែលមានការយល់ព្រមទៅវិញទៅមកជាលាយលក្ខអក្សរ ដោយភាគីទាំងអស់ ។

## មាត្រា១៥

## ការតម្កល់ឯកសារ

ចំពោះរដ្ឋជាសមាជិកអាស៊ានទាំងអស់ កិច្ចព្រមព្រៀងនេះ នឹងតំកល់ទុកនៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកមានសិទ្ធិផ្តល់ច្បាប់ចំលងដោយមានបញ្ជាក់ត្រឹមត្រូវ នៃកិច្ចព្រមព្រៀងនេះមួយច្បាប់ជាប្រញាប់ ដល់រដ្ឋជាសមាជិកអាស៊ាននីមួយៗ ។

## មាត្រា១៦

## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន នៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៣ ។

២. ភាគីទាំងអស់ ត្រូវបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួន អោយបានមុនថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៣ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

៣. ចំពោះភាគីណាដែលមិនអាចបញ្ចប់បែបបទផ្ទៃក្នុងសំរាប់អនុវត្តកិច្ចព្រមព្រេងនេះទេ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនោះ នៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្តើមអនុវត្តនៅពេលដែលគេបានបញ្ចប់បែបបទផ្ទៃក្នុងរបស់គេ ។

៤. នៅពេលដែលភាគីមួយបានបញ្ចប់បែបបទផ្ទៃក្នុង សំរាប់អនុវត្តកិច្ចប្រមព្រៀងនេះហើយ ភាគីនោះត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដល់ភាគីដទៃទៀតដើម្បីជ្រាប ។

**ដើម្បីជាសក្ខីភាព យើង** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

**ធ្វើនៅ** រាជធានីភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ ជាពីរច្បាប់ ជាភាសាអង់គ្លេស ។

**ប្រ៊ុយណេដារូសាឡាំ**

HAJI HASSANAL BOLKIAH

ស្តេចស៊ុលតង់ ប្រ៊ុយណេដារូសាឡាំ

**ព្រះរាជាណាចក្រកម្ពុជា**

ហ៊ុន សែន

នាយករដ្ឋមន្ត្រី

**សាធារណរដ្ឋប្រជាមានិតចិន**

ZHU RONGJI

នាយករដ្ឋមន្ត្រី

**សាធារណរដ្ឋឥណ្ឌូនេស៊ី**

MEGAWATI SOEKARNOPUTRI

ប្រធានាធិបតី

**សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

BOUNNHANG VORACHITH

នាយករដ្ឋមន្ត្រី

**សម៉ាឡេស៊ី**

MAHATHIR BIN MOHAMAD

នាយករដ្ឋមន្ត្រី

**សហភាពភូមា**

SENIOR GENERAL THAN SHWE

ប្រធានក្រុមប្រឹក្សាសន្តិភាពរដ្ឋ និងអភិវឌ្ឍន៍

និងជានាយករដ្ឋមន្ត្រី

**សធារណរដ្ឋហ្វីលីពីន**

GLORIA MACAPAGAL-ARROYO

ប្រធានាធិបតី

**សាធារណរដ្ឋសិង្ហបុរី**

GOH CHOK TONG
នាយករដ្ឋមន្ត្រី

**រាជាណាចក្រថៃឡង់ដ៍**

POL.LT. COL. THAKSIN SHINAWATRA
នាយករដ្ឋមន្ត្រី

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

PHAN VAN KHAI
នាយករដ្ឋមន្ត្រី ៧

# បញ្ជីលើកលែងនៃក្រុមប្រទេសដកចេញផលិតផលពីកម្មវិធីប្រមូលផលដើមដៃ នៅក្រោមមាត្រាទី៦ (៣) (ក) (១) [២]

ក. ក្រុមប្រទេសដែលបានវាយនាមបន្តបន្ទាប់នេះ បានបញ្ចប់ការចរចារបស់ពួកគេជាមួយគ្នា ទៅវិញទៅមក ហើយបញ្ជីលើកលែងរបស់ពួកគេមានដូចខាងក្រោម :

ក- ប្រទេសប្រ៊ុយណេ ពុំមានផលិតផលណាលើកលែងទេ ។

ខ- ប្រទេសសឹង្ហបូរី ពុំមានផលិតផលណាលើកលែងទេ ។

គ- ប្រទេសថៃឡង់ដ៍ ពុំមានផលិតផលណាលើកលែងទេ ។

ឃ- ប្រទេសឥណ្ឌូនេស៊ី ផលិតផលខាងក្រោមត្រូវបានដកចេញ ។

| S/No. | HS-Code | បរិយាយមុខទំនិញ |
|---|---|---|
| ១ | ០៧១០១០០០០ | ពោតផ្អែម |

ង. ប្រទេសចិន ពុំមានផលិតផលណាលើកលែង ចំពោះប្រទេសប្រ៊ូណេ ឥណ្ឌូនេស៊ី សឹង្ហបូរី និងថៃឡង់ដ៍ទេ ។

ខ. ក្រុមប្រទេសដែលមិនបានបញ្ចប់ការចរចារបស់ពួកគេជាមួយគ្នាទៅវិញទៅមក និងត្រូវតែបញ្ចប់ការចរចាស្តីពីបញ្ជីលើកលែងរបស់ពួកគេ នៅថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៣ :

ក. ប្រទេសកម្ពុជា

ខ. ប្រទេសឡាវ

គ. ប្រទេសម៉ាឡេស៊ី

ឃ. ប្រទេសមីយ៉ានម៉ា

ង. ប្រទេសវៀតណាម

ច. ប្រទេសចិន ជាមួយ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ។ល

[២] មិនអាចអនុវត្តបានចំពោះប្រទេសហ្វីលីពីន

## ផលិតផលជាក់លាក់ដែលគ្របដណ្តប់ដោយ
## កម្មវិធីប្រមូលផលដើមដៃនៅក្រោមមាត្រាទី៦ (៣) (ក) (៣) [៣]

ក. ក្រុមប្រទេសដែលមានរាយនាមបន្តបន្ទាប់នេះ បានបញ្ចប់ការចរចាជាមួយគ្នាទៅវិញទៅមក ហើយបញ្ជីជាក់លាក់របស់ពួកគេមានដូចខាងក្រោម :

ក. ប្រទេសប្រ៊ុយណេ នឹងយល់ព្រមចំពោះការចូលរួមនៅក្នុងផលិតផលជាក់លាក់ដែលបានព្រមព្រៀងគ្នារួច ឬនឹងត្រូវយល់ព្រមនៅក្នុងការចរចាបន្តទៀតរវាង ចិន និងសមាជិកអាស៊ានដ៏ទៃទៀត ។

ខ. ប្រទេសសិង្ហបូរី នឹងយល់ព្រមចំពោះការចូលរួមនៅក្នុងផលិតផលជាក់លាក់ដែលបានព្រមព្រៀងគ្នារួច ឬនឹងត្រូវយល់ព្រមនៅក្នុងការចរចាបន្តទៀតរវាងចិន និងសមាជិកអាស៊ានដ៏ទៃទៀត ។

គ- ប្រទេសចិន នឹងពន្យាពេលចំពោះប្រទេសប្រ៊ុយណេ និងសិង្ហបូរី នូវសម្បទានពន្ធគយមួយចំនួន ចំពោះផលិតផលជាក់លាក់ ដែលបានយល់ព្រមរួចហើយ ឬនឹងត្រូវយល់ព្រមចរចាបន្តទៀត ជាមួយនឹងសមាជិកអាស៊ានមួយចំនួន ។

ខ. ក្រុមប្រទេសដែលមិនបានបញ្ចប់ការចរចារបស់ពួកគេជាមួយគ្នាទៅវិញទៅមក និងត្រូវតែបញ្ចប់ការចរចាលើបញ្ជីលើកលែងរបស់ពួកគេ នៅថ្ងៃទី១ ខែមិនា ឆ្នាំ២០០៣ :

ក. ប្រទេសកម្ពុជា

ខ. ប្រទេសឡាវ

គ. ប្រទេសម៉ាឡេស៊ី

ឃ. ប្រទេសមីយ៉ានម៉ា

ង. ប្រទេសវៀតណាម

ច. ប្រទេសចិន ជាមួយប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ៧

---

៣ -មិនអាចអនុវត្តបានចំពោះប្រទេសហ្វីលីពីន

## ក. ផលិតផល៣ប្រភេទសំរាប់កាត់បន្ថយនិងលុបបំបាត់ពន្ធគយតាមការកំណត់ នៅក្រោម មាត្រាទី៦ (៣) (ខ) (១) [៣]

ប្រភេទផលិតផលទាំង៣ ត្រូវបានកំណត់ដូចខាងក្រោម :

### (១) ប្រភេទទី១

សំរាប់ប្រទេសចិន និងអាស៊ាន៦ ត្រូវយោងទៅលើផលិតផលទាំងអស់ដែលមានអត្រាពន្ធគយអនុវត្ត MFN ខ្ពស់ជាង ១៥% ។

សំរាប់ប្រទេសសមាជិកអាស៊ានថ្មី ត្រូវយោងទៅលើផលិតផលទាំងអស់ដែលមានអត្រាពន្ធគយអនុវត្ត MFN ៣០% ឬខ្ពស់ជាង ។

### (២) ប្រភេទទី២

សំរាប់ប្រទេសចិន និងអាស៊ាន៦ ត្រូវយោងទៅលើផលិតផលទាំងអស់ ដែលមានអត្រាពន្ធគយអនុវត្ត MFN រវាង៥% (ក្នុងបញ្ជីដាក់បញ្ចូល) និង១៥% (ក្នុងបញ្ជីដាក់បញ្ចូល) ។

សំរាប់ប្រទេសសមាជិកអាស៊ានថ្មី ត្រូវយោងទៅលើផលិតផលទាំងអស់ដែលមានអត្រាពន្ធគយអនុវត្ត MFN រវាង១៥%(ក្នុងបញ្ជីដាក់បញ្ចូល) និង ៣០% (ក្នុងបញ្ជីលើកលែង) ។

### (៣) ប្រភេទទី៣

សំរាប់ប្រទេសចិន និងអាស៊ាន៦ ត្រូវយោងទៅលើផលិតផលទាំងអស់ដែលមានអត្រាពន្ធគយអនុវត្ត MFN ទាបជាង ៥% ។

សំរាប់ប្រទេសសមាជិកអាស៊ានថ្មី ត្រូវយោងទៅលើផលិតផលទាំងអស់ដែលមានអត្រាពន្ធគយអនុវត្ត MFN ទាបជាង ១៥% ។

## ខ. ក្របខ័ណ្ឌពេលវេលាអនុវត្តន៍នៅក្រោមមាត្រា៦ (៣) (ខ) (១)

កម្មវិធីប្រមូលផលដើមដៃ ត្រូវតែបានអនុវត្តមិនលើសពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ ដូចខាងក្រោម :

---

៣ -មិនអាចអនុវត្តបានចំពោះប្រទេសហ្វីលីពីន

-ផលិតផលប្រភេទទី៣

| ប្រទេស | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ | មិនលើសពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ |
|---|---|---|---|---|---|---|---|
| វៀតណាម | ៥% | ៥% | ០-៥% | ០-៥% | ០% | ០% | ០% |
| ឡាវ និងមីយ៉ាន់ម៉ា | - | - | ៥% | ៥% | ០-៥% | ០% | ០% |
| កម្ពុជា | - | - | ៥% | ៥% | ០-៥% | ០-៥% | ០% |

## សកម្មភាពនៅក្រោមមាត្រាទី៦ (៥)

ក. ការពន្លឿនការអនុវត្តន៍នៃការតភ្ជាប់ផ្លូវរថភ្លើង សឹង្ហបុរី-គុណមិញ និងគំរោងផ្លូវហៃរ៉េបាងកក-គុណមិញ នៅក្រោមគំរោងកិច្ចព្រមព្រៀងនីមួយ១ នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គ អាស៊ាន (AMBDC) និងកម្មវិធីមហាអនុតំបន់មេគង្គ (GMS)។

ខ. ការអនុវត្តន៍ផែនការរយៈពេលមធ្យម និងវែង សំរាប់ការអភិវឌ្ឍន៍ទាំងមូលនៃមហាអនុតំបន់មេគង្គ (GMS) បានរៀបចំផែនការដោយកិច្ចប្រជុំកំពូល (GMS) លើកទី១ បានប្រារព្ធធ្វើឡើងនៅកម្ពុជា។

គ. តួនាទីនៃការសំរបសំរួលនៅក្នុងប្រទេសសមាជិកអាស៊ាន និងចិន ជាមជ្ឈមណ្ឌលធ្វើការសំរបសំរួល និងជំរុញ តាមរយៈ នីតិវិធីជាក់លាក់ និងយន្តការដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគរវាងដៃគូរទាំងអស់។

ឃ. ដំណើរការស្រាវជ្រាវដែលអាចធ្វើទៅបាន ដើម្បីអភិវឌ្ឍន៍ដល់ការសំរួលការទទួលស្គាល់គ្នាទៅវិញទៅមក (MRAs) នៃការចាប់អារម្មណ៍នៅក្នុងតំបន់ទាំងសងខាង ឧទាហរណ៍ ផលិតផលកសិកម្ម អេឡិច-ត្រូនិក និងឧបករណ៍អេឡិចត្រូនិក និងបានបញ្ចប់ជាមួយនឹងគំរោងពេលវេលាដែលបានឯកភាព។

ង. បង្កើតយន្តការសហប្រតិបត្តិការរវាងស្ថាប័នស្តង់ដារ និងភាពស្របគ្នារបស់ប្រទេសទាំងអស់ នៅក្នុងគំនិតធ្វើឱ្យប្រសើរឡើងដល់ការសំរបសំរួលពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យ ផ្សេង១ទៀត។

ច. ការអនុវត្តន៍អនុស្សរណៈយល់យោគគ្នាស្តីពីកិច្ចប្រតិបត្តិការផ្នែកកសិកម្ម រវាងប្រទេសហត្ថលេខីនៅក្នុងខែវិច្ឆិការ ឆ្នាំ២០០២។៧

ឆ. សេចក្តីបញ្ចប់អនុស្សរណៈយល់យោគគ្នាស្តីពីកិច្ចប្រតិបត្តិការកសិកម្ម រវាងដៃគូរទាំងអស់នៅក្នុងផ្នែកបច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ (ICT) ។

ជ. កម្មវិធីជាក់ស្តែងនៃការអភិវឌ្ឍន៍ ជាមួយនឹងជាគន្លឹះ សំរាប់ពង្រឹងកិច្ចសហប្រតិបត្តិការបន្តនៅក្នុងតំបន់ លើផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស ការប្រើប្រាស់នៅក្នុងចំណោមយន្តការដ៏ទៃទៀត តាមរយៈមូលនិធិ សហប្រតិបត្តិការអាស៊ាន-ចិន ។

ឈ. បង្កើតកម្មវិធីបច្ចេកទេសជាក់លាក់ជាច្រើនជាមួយនឹងគន្លឹះ ដើម្បីបន្តការជួយប្រទេសសមាជិកអាស៊ានថ្មី នៅក្នុងការបង្កើនសមត្ថភាពរបស់ពួកគេ សំរាប់សមាហរណកម្មក្នុងតំបន់ និងសំរបសំរួលនៃដំណើរការចូលជាសមាជិក WTO របស់ប្រទេសមិនមែនជាសមាជិក WTO ។

ញ. ការបង្កើតយន្តការកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគយនៃដៃគូរទាំងអស់ ជាមួយនឹងគន្លឹះ ដើម្បីពង្រីកការសំរបសំរួលពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យដទៃៗទៀត ។

ដ. ការបង្កើតយន្តការសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធរបស់ដៃគូរទាំងអស់ នៅក្នុងដំណើរសិក្សាការការពារកម្មសិទ្ធិបញ្ញា ។៷

...ដ្ឋាន រសេចា និងបច្ចេកទេស
...កដ្ឋានស្រាវជ្រាវ...
លេខ ........៥៨៣........
ថ្ងៃទី២២.០៧.០៧ ម៉ោង
បញ្ជូនទៅ ................

# ពិធីសារនៃការធ្វើវិសោធនកម្មលើ
# កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា រាជាណាចក្រថៃឡង់ដ៏ សាធារណរដ្ឋសង្គមនិយមវៀតណាម ជាសមាជិកសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ហៅកាត់ថា "អាស៊ាន" ឬរដ្ឋជាសមាជិកអាស៊ាន) និង សាធារណរដ្ឋប្រជាមានិតចិន ("ចិន") ។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងអាស៊ាន និងចិន (ហៅកាត់ថា "កិច្ចព្រមព្រៀងក្របខណ្ឌ" ដែលបានចុះហត្ថលេខានៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

**ដោយទទួលស្គាល់** ថា ភាគីនីមួយៗ អាចបង្កើនល្បឿននូវការកាត់បន្ថយ និងការលុបបំបាត់ពន្ធរបស់ខ្លួនចំពោះផលិតផលដែលគ្របដណ្តប់នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ រួមទាំងការសន្យាទាំងឡាយ ដែលគ្របដណ្តប់នៅក្រោមកម្មវិធីប្រមូលផលដើមដៃនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**ដោយទទួលស្គាល់** ផងដែរ នូវការទាមទារឱ្យរដ្ឋជាសមាជិកអាស៊ាននានា ធ្វើការបញ្ចប់ការចរចារបស់ពួកគេជាមួយភាគីចិន ចំពោះកម្មវិធីប្រមូលផលដើមដៃ ដែលបានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**ដោយស្វែងរក** ដើម្បីបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងក្រខ័ណ្ឌនូវវិធានប្រភពដើមទំនិញ ដែលអាចអនុវត្តទៅលើផលិតផល ដែលគ្របដណ្តប់នៅក្រោមកម្មវិធីប្រមូលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**ដោយស្វែងរក** ផងដែរ ដើម្បីកែតំរូវឡើងវិញនូវខ្លឹមសារនៃឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ដែលមានស្រាប់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដើម្បីបញ្ចូលនូវកិច្ចព្រមព្រៀងប្រមូលផលដើមដៃមួយចំនួនជាបន្តបន្ទាប់ រវាងរដ្ឋជាសមាជិកអាស៊ានមួយចំនួន និងចិន ដើម្បីបញ្ចូលលេខកូដប្រព័ន្ធស្របគ្នា (HS Codes) និងការបរិយាយមុខផលិតផល ។

**ដោយប្រាថ្នា** បកស្រាយឱ្យបានច្បាស់នូវការអនុវត្តន៍បញ្ញត្តិទាំងឡាយនៃកម្មវិធីប្រមូលផល ដើមដៃនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**ដោយប្រាថ្នា** ផងដែរ ដើម្បីកំណត់ពេលវេលា និងលក្ខខ័ណ្ឌសំរាប់ធ្វើការពន្លឿនការកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយ ចំពោះផលិតផលដែលគ្របដណ្តប់នៅក្រោមកម្មវិធីប្រមូលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ហើយការបង្កើតនូវកិច្ចព្រមព្រៀងទាំងនេះដើម្បីធ្វើជាវណាបកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**ដោយកត់សំគាល់** ថា មាត្រា១៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌបានទ្រទ្រង់នូវរាល់ការធ្វើវិសោធនកម្មទាំងឡាយ ដែលត្រូវបានព្រមព្រៀងគ្នាជាលាយល័ក្ខអក្សរ ។

**បានព្រមព្រៀងគ្នាដូចខាងក្រោម :**

## មាត្រា១

## ការធ្វើវិសោធនកម្មលើមាត្រា៦ (៣) (ក) (៤) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

មាត្រា ៦ (៣) (ក) (៤) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងត្រូវបានលុបចោល និងត្រូវជំនួសទាំងស្រុងដោយមាត្រា ៦ (៣) (ក) (៤) ដូចមានចែងខាងក្រោម:

"(៤) ចំពោះភាគីទាំងឡាយណា ដែលមិនអាចធ្វើបញ្ចប់នូវបញ្ជីផលិតផលសមស្របនៅក្នុងឧបសម្ព័ន្ធទី១ ឬឧបសម្ព័ន្ធ២ បញ្ជីទាំងនេះអាចរៀបចំបន្តទៅទៀតបាន ដោយមានការព្រមព្រៀងគ្នា ដែលស្របជាមួយនឹងក្របខ័ណ្ឌពេលវេលាអនុវត្តន៍ ដែលបានចែងក្នុងឧបសម្ព័ន្ធទី៣ នៃកិច្ចព្រមព្រៀងនេះ" ។

## មាត្រា២

## ការធ្វើវិសោធនកម្មលើមាត្រា៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

មាត្រា៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវជំនួសដោយមាត្រាទី៦ (៣) (ខ) (១) ថ្មី ដូចមានចែងខាងក្រោម:

"(១) ផលិតផលទាំងអស់ដែលគ្របដណ្តប់នៅក្រោមកម្មវិធីប្រមូលផលដើមដៃ ត្រូវបែងចែកជា៣ប្រភេទទំនិញសំរាប់ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ ដូចបានកំណត់ និងដើម្បីអនុវត្តឱ្យស្របតាមក្របខ័ណ្ឌពេលវេលា ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ នៃកិច្ចព្រមព្រៀងនេះ។ កថាខ័ណ្ឌនេះ មិនបានឃាត់ឃាំងភាគីណាមួយ ពីការបង្កើនល្បឿននៃការកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយ ប្រសិនបើគេមានបំណងធ្វើដូចនេះ ដោយផ្អែកតាមលក្ខខ័ណ្ឌខាងក្រោម:

(១) ភាគីមួយអាចបង្កើនល្បឿនការកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយរបស់ខ្លួនចំពោះភាគីទាំងអស់ ដោយឈរលើមូលដ្ឋានជាឯកតោភាគី នៅក្រោមមាត្រានេះ។

(២) នៅក្រោមមាត្រានេះ ប្រទេសសមាជិកអាស៊ានមួយ ឬច្រើន អាចធ្វើការចរចា និងអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ជាមួយភាគីចិនបានផងដែរ ដើម្បីបង្កើនល្បឿននៃការកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយរបស់ខ្លួន។

(៣) មុនពេលចាប់ផ្តើមធ្វើការចរចាលើកិច្ចព្រមព្រៀងណាមួយ អនុលោមទៅតាមកថាខ័ណ្ឌទី២នៃមាត្រា៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ ភាគីទាំអស់ដែលសំរេចចិត្តធ្វើការចរចារបៀបនេះ ត្រូវជូនដំណឹងជាលាយលក្ខ័អក្សររួមគ្នាដល់ប្រទេសសមាជិកអាស៊ាន យ៉ាងតិច មួយ

ខែមុនចាប់ផ្តើមចរចាបែបនេះ ដើម្បីរដ្ឋជាសមាជិកមួយ ឬច្រើន អាចចូលរួមធ្វើការចរចាបែបនេះជាមួយភាគីខាងដើមបាន ប្រសិនបើសមាជិកទាំងនោះ មានបំណងចូលរួម ។ រដ្ឋជាមាជិកអាស៊ានណាមួយដែលមានបំណងចូលរួមចរចាបែបនេះ ត្រូវជូនដំណឹងដល់ភាគីដើម ដោយប្រាប់អំពីគោលបំណងចូលរួមការចរចាបែបនេះរបស់ខ្លួន ជាលាយលក្ខ័អក្សរ និងត្រូវផ្តល់នូវលិខិតចំលងនៃការជូនដំណឹងទាំងនោះ ដល់ប្រទេសសមាជិកអាស៊ានដទៃទៀត តាមរយៈលេខាធិការដ្ឋានអាស៊ាន ។

(៤) រដ្ឋជាមាជិកអាស៊ានីមួយៗ ត្រូវបានអនុញ្ញាតឱ្យបញ្ចប់នូវកិច្ចព្រមព្រៀងណាមួយ ដោយស្របនៅនឹងអនុថាខ័ណ្ឌទី២ នៃមាត្រា ៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ (កិច្ចព្រមព្រៀងក្របខ័ណ្ឌកែប្រែថ្មី) ដែលបានចែងថា អនុកថាខ័ណ្ឌនេះ បានចងការធ្វើកិច្ចព្រមព្រៀងបែបនេះ ឱ្យមានភ្ជាប់មកជាមួយនូវកញ្ចប់សន្យាទាំងមូល អំពីទំហំផលិតផល កម្មវិធីពន្ធគយ និងក្របខ័ណ្ឌពេលវេលាសំរាប់អនុវត្តន៍ ដូចដែលបានបង្គាប់នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវធ្វើបញ្ចប់នោះ ។ ចំពោះប្រទេសសមាជិកអាស៊ានថ្មី នឹងត្រូវបានផ្តល់នូវប្រព្រឹត្តិកម្មពិសេស និងដោយឡែក និងផ្តល់ភាពទន់ភ្លន់នៅលើក្របខ័ណ្ឌពេលវេលាអនុវត្តន៍ផងដែរ ។

(៥) ក្នុងការអនុវត្តន៍ការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធគយ ដែលស្ថិតក្រោមកិច្ចព្រមព្រៀងណាមួយ ដែលបានធ្វើចប់សព្វគ្រប់ ស្របតាមអនុកថាខ័ណ្ឌទី២នៃមាត្រា ៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ ប្រភពដើមទំនិញ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ នឹងអាចត្រូវយកមកអនុវត្តន៍បាន ។

(៦) កិច្ចព្រមព្រៀងណាមួយ ដែលបានធ្វើបញ្ចប់ ស្របតាមវគ្គកថាខ័ណ្ឌទី២ នៃមាត្រា ៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ ត្រូវធ្វើសេចក្តីជូនដំណឹងរួមគ្នាដោយភាគីនៃ កិច្ចព្រមព្រៀងមួយនោះ ដល់ប្រទេសសមាជិកអាស៊ានដទៃទៀត តាមរយៈលេខាធិការដ្ឋានអាស៊ាន ដែលត្រូវភ្ជាប់ជាឧបសម្ព័ន្ធរបស់កិច្ចព្រមព្រៀងនេះ ដោយមិនចាំបាច់មានពិធីសារធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះទេ ។ លេខាធិការដ្ឋានអាស៊ាន ត្រូវផ្តល់ដល់រដ្ឋជាសមាជិកអាស៊ានទាំងអស់ និងចិន នូវច្បាប់ចំលងកិច្ចព្រមព្រៀង ដែលបានធ្វើបញ្ចប់នេះ ដោយមានចុះលេខឧបសម្ព័ន្ធត្រឹមត្រូវ ។

(៧) រដ្ឋជាសមាជិកអាស៊ានណាមួយ ដែលប្រាថ្នាចង់ធ្វើការបញ្ចប់កិច្ចព្រមព្រៀងណាមួយស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងដល់ភាគីដើមនៃកិច្ចប្រមព្រៀង ពីគោលបំណង ចូរួមរបស់គេជាលាយល័ក្ខអក្សរ និងត្រូវផ្តល់ច្បាប់ចំលង នៃការជូនដំណឹងនោះ ដល់បណ្តារដ្ឋសមាជិកអាស៊ាន តាមរយៈ លេខាធិការដ្ឋានអាស៊ាន ។

(៨) កិច្ចព្រមព្រៀងបង្កើនល្បឿនណាមួយដែលបានចរចាបញ្ចប់ស្របទៅនឹងពេលកំណត់ និងលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៦ (៣) (ខ) (១) នៃកិច្ចព្រមព្រៀងនេះ រួមទាំងកិច្ចព្រមព្រៀង

បង្កើនល្បឿនណាមួយ ដែលបានសំរេចមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវបង្កើតជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៣

## ការធ្វើវិសោធនកម្មលើមាត្រា៦ (៣) (គ) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

១. មាត្រា ៦ (៣) (គ) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងត្រូវធ្វើវិសោធនកម្ម ដោយដាក់ចូលនូវកថាខ័ណ្ឌថ្មីមួយជាបន្ទាន់ បន្ទាប់ពីមាត្រា៦ (៣) (គ) ចាស់ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវបានកែប្រែ ហើយធ្វើការដាក់លេខកថាខ័ណ្ឌទាំងនោះទៅជាមាត្រា៦ (៣)(គ) (១) មាត្រា៦ (៣) (គ) (២) និងមាត្រា៦ (៣) (គ) (៣) ដូចខាងក្រោមៈ

**(គ) វិធានប្រភពដើមទំនិញ**

(១) វិធានប្រភពដើមទំនិញ ត្រូវបានចែងក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងនេះ ។

(២) អត្ថបទនៃប្រភពដើមទំនិញ ត្រូវអាចអនុវត្តបានចំពោះផលិតផលទាំងឡាយ ដែលគ្របដណ្តប់នៅក្រោមកម្មវិធីទទួលផលដើមដៃ ។

(៣) ការចរចាស្តីពីវិធានផលិតផលជាក់លាក់ ដែលមានចែងក្នុងឯកសារភ្ជាប់ ខ នៃវិធានប្រភពដើមទំនិញ ត្រូវចាប់ផ្តើមអនុវត្តក្នុងខែមករា ឆ្នាំ២០០៤ ។

២. កិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវបានធ្វើវិសោធនកម្ម ដោយបញ្ចូលជាឧបសម្ព័ន្ធទី ៥ ជាបញ្ញត្តិស្តីពីវិធានប្រភពដើមទំនិញ ដែលមានចែងនៅក្នុងសេចក្តីបន្ថែមទី១ នៃពិធីសារនេះ ។

## មាត្រាទី៤

## ការធ្វើវិសោធនកម្មដើម្បីបញ្ចូលមាត្រា១២ក ថ្មី នៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ

កិច្ចព្រមព្រៀងក្របខ័ណ្ឌនឹងត្រូវធ្វើវិសោធនកម្ម ដោយបញ្ចូលមាត្រា ១២ក ថ្មី ភ្លាម បន្ទាប់ពីមាត្រាទី១២ចាស់ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវបានកែប្រែ ដែលមានដូចខាងក្រោមៈ

## " មាត្រា១២ក

## កិច្ចព្រមព្រៀងនៅក្រៅកិច្ចព្រមព្រៀងនេះ

គ្មានបញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវរារាំង ឬហាមឃាត់ រដ្ឋជាមាជិកអាស៊ានណាមួយ ពីការបង្កើតកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ជាមួយចិន និង/ឬជាមួយប្រទេសសមាជិកអាស៊ានទាំងអស់ ពាក់ព័ន្ធនៅក្នុងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគទុន និង/ឬ ធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្សេងៗទៀត នៅក្រៅពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះឡើយ។ បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវអនុវត្តទៅលើកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី បែបនេះទេ " ។

## មាត្រា៥
## ការជំនួសឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

ឧបសម្ព័ន្ធទី១បច្ចុប្បន្ន នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងត្រូវបានជំនួសដោយឧបសម្ព័ន្ធទី១ថ្មី ដូចមានចែងក្នុងសេចក្ដីបន្ថែម២ នៃពិធីសារនេះ ។

## មាត្រា៦
## ការជំនួសឧបសម្ព័ន្ធ២នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

ឧបសម្ព័ន្ធ២បច្ចុប្បន្ននៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងត្រូវបានជំនួសដោយឧបសម្ព័ន្ធ២ថ្មី ដូចមានចែងក្នុងសេចក្ដីបន្ថែមទី៣នៃពិធីសារនេះ ។

## មាត្រា៧
## ការបញ្ចូលការសន្យានៅក្នុងកម្មវិធីទទួលផលដើមដៃ

ភាគីទាំងអស់ ត្រូវបញ្ចូលការសន្យាទាំងឡាយរបស់ខ្លួន នៅក្រោមកម្មវិធីទទួលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ទៅក្នុងកម្មវិធីសម្បទានប្រមូលផលដើមដៃរបស់ខ្លួន ដូចមានចែងនៅក្នុងសេចក្ដីបន្ថែម២ និងសេចក្ដីបន្ថែម៣នៃពិធីសារនេះ ដែលនឹងបង្កើតបានជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយកម្មវិធីសន្យានេះ នឹងត្រូវតម្កល់ទុកភ្លាមៗ នៅឯលេខាធិការដ្ឋានអាស៊ាន ។

## មាត្រា៨
## ការចូលជាធរមាន

១. ពិធីសារនេះនឹងបង្កើតជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយនិងត្រូវចូលជាធរមានបន្ទាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

២. ចំពោះប្រទេសសមាជិកអាស៊ាន ពិធីសារនេះនឹងត្រូវតំកល់ទុកជាមួយលេខាធិការដ្ឋានអាស៊ាន ដែលនឹងត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវមួយច្បាប់ ដល់រដ្ឋជាសមាជិកនីមួយៗ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពេញលេញពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិចិន ។

**ធ្វើនៅ** ទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី៦ ខែតុលាឆ្នាំ២០០៣ ជាពីរច្បាប់ ជាភាសាអង់គ្លេស ។

ប្រ៊ុយណេដារូសាឡាំ

**Pehin Dato Abdul Rahman Taib**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងធនធាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ចម ប្រសិទ្ធ**

រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋប្រជាមានិតចិន**

**Yu Guangzhou**
អនុរដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋឥណ្ឌូនេស៊ី**

**Rini M.S Soewandi**
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

**សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

**Soulivong Daravong**
រដ្ឋមន្ត្រីពាណិជ្ជកម្ម

**ម៉ាឡេស៊ី**
**Dato 'Seri Rafidah Aziz**
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ

**សហភាពមីយ៉ាន់ម៉ា**

**U Khaw Thu**

អនុរដ្ឋមន្ត្រីការបរទេស

**សាធារណរដ្ឋហ្វីលីពីន**

**MAR Roxas**

រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

**សាធារណរដ្ឋសិង្ហបុរី**

**B.G.(NS) George Yong-Boon Yeo**

រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

**រាជាណាចក្រថៃឡង់ដ៍**

Adisai Bodharamik

រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

Truong Dinh Tuyen

រដ្ឋមន្ត្រីពាណិជ្ជកម្ម

# កិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មទំនិញ
# នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ
# រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

សេចា និងបច្ចេកទេស
...ន ស្រាវជ្រាវច្បាប់
...៥៩៣...

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ("ឡាវ PDR") ម៉ាឡេស៊ី សហភាពមីយ៉ាន់មា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា "អាស៊ាន" ឬ "រដ្ឋជាសមាជិកអាស៊ាន" ឬសមាជិកនីមួយៗ "រដ្ឋជាសមាជិកអាស៊ានមួយ") និងសាធារណរដ្ឋប្រជាមានិតចិន ("ចិន")។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (កិច្ចព្រមព្រៀងក្របខ័ណ្ឌ) រវាងអាស៊ាន និងចិន (ហៅកាត់ថា "ភាគីទាំងអស់" ឬសមាជិកនីមួយៗ គឺសំដៅទៅលើរដ្ឋជាសមាជិកអាស៊ានមួយ ឬចិន គឺជា "ភាគីមួយ") ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ាន និងចិន នៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ និងពិធីសារធ្វើវិសោធកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ លើកម្មវិធីប្រមូលផលដើមដៃ ដែលត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចនៃភាគីទាំងអស់ នៅទីក្រុងបាលី ប្រទេសឥណ្ឌូណេស៊ី នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៣។

**ដោយរំលឹកឡើងវិញ** បន្ថែមទៀតនូវមាត្រា ២ (ក) មាត្រា ៣ (១) និងមាត្រា ៨ (១) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដែលឆ្លុះបញ្ចាំងនូវការសន្យារបស់ភាគីទាំងអស់ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ដែលគ្របដណ្ដប់ទៅលើពាណិជ្ជកម្មទំនិញនៅឆ្នាំ២០១០ សំរាប់អាស៊ាន៦ និងចិន និងនៅឆ្នាំ២០១៥ សំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី។

**ដោយអះអាងជាថ្មី** នូវការសន្យារបស់ភាគីទាំងអស់ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន នៅក្នុងក្របខ័ណ្ឌពេលវេលាជាក់លាក់ ដោយផ្ដល់នូវភាពទន់ភ្លន់ដល់ភាគីទាំងអស់ ដើម្បីដោះស្រាយចំពោះវិស័យដែលមានវេទយិតភាពនានារបស់ពួកគេ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

**បានព្រមព្រៀងដូចខាងក្រោមៈ**

## មាត្រា១
## និយមន័យ

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ និយមន័យខាងក្រោមត្រូវអនុវត្តបាន បើពុំមានបរិបទណាតម្រូវឱ្យផ្ទុយពីនេះ:

(ក) "WTO" មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក ។

(ខ) "GATT 1994" មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ដោយរាប់បញ្ចូលទាំងឧបសម្ព័ន្ធ ១ (កំណត់សំគាល់ និងបញ្ញត្តិបន្ថែម) ផង ។

(គ) "ASEAN 6" សំដៅទៅលើ ប្រទេសប្រ៊ុយណេដារូសាឡាំ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃឡង់ដ៏ ។

(ឃ) "រដ្ឋជាសមាជិកអាស៊ានថ្មី" សំដៅលើប្រទេសកម្ពុជា ឡាវ PDR មីយ៉ានម៉ា និងវៀតណាម

(ង) "អត្រាពន្ធគយអនុវត្ត MFN" ត្រូវរាប់បញ្ចូលទាំងអត្រាក្នុងកូតាផងដែរ ហើយ :

(១) ក្នុងករណីរដ្ឋជាសមាជិកអាស៊ាន (ដែលជាសមាជិកនៃអង្គការ WTO ចាប់តាំងពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣) និងចិន ត្រូវយោងតាមអត្រាអនុវត្តរបស់ភាគីនីមួយៗ ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០០៣ ។

(២) ក្នុងករណីរដ្ឋជាសមាជិកអាស៊ាន (ដែលមិនមែនជាសមាជិកនៃអង្គការ WTO ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣) ត្រូវយោងទៅតាមអត្រាដែលបានអនុវត្តចំពោះចិន ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣)

(ច) "វិធានការមិនមែនពន្ធគយ" ត្រូវរាប់បញ្ចូលទាំងរបាំងមិនមែនពន្ធគយផងដែរ

(ឆ) "AEM" មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

(ជ) "MOFCOM" មានន័យថា ក្រសួងពាណិជ្ជកម្មចិន

(ឈ) "SEOM" មានន័យថា កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន

## មាត្រា២

## ប្រព្រឹត្តិកម្មជាតិស្តីពីពន្ធ និងបទបញ្ញត្តិក្នុងស្រុក

ភាគីនីមួយៗ ត្រូវតែស្រុះស្រួលគ្នាធ្វើប្រព្រឹត្តិកម្មជាតិ ទៅលើផលិតផលរបស់ភាគីផ្សេងៗទៀតទាំងអស់ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដោយអនុលោមទៅតាមមាត្រា III នៃ GATT 1994 ។ ជាចុងក្រោយ បញ្ញត្តិនៃមាត្រា III នៃ GATT 1994 ត្រូវបានដាក់បញ្ចូល និងបង្កើតជាផ្នែកដ៏សំខាន់មួយនៅក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រា៣

## ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ

១. កម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ របស់ភាគីទាំងអស់ ត្រូវទាមទារឱ្យធ្វើការកាត់បន្ថយ និងលុបបំបាត់នូវអត្រាពន្ធគយ អនុវត្ត MFN នៅលើបន្ទាត់ពន្ធគយដែលបានចុះបញ្ជី ជាបន្តបន្ទាប់ នៅពេលដែលអាចធ្វើទៅបាន ដោយស្របទៅតាមមាត្រានេះ ។

២. បន្ទាត់ពន្ធគយដែលត្រូវបញ្ចូលទៅក្នុងកម្មវិធីកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ នៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវរួមបញ្ចូលនូវបន្ទាត់ពន្ធគយទាំងអស់ ដែលមិនគ្របដណ្តប់ដោយកម្មវិធីប្រមូលផលដើមដៃនៅក្រោមមាត្រា៦ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយបន្ទាត់ពន្ធគយបែបនេះ ត្រូវចាត់បញ្ចូលនៅក្នុងជំពូកសំរាប់កាត់បន្ថយ និងលុបបំបាត់ពន្ធគយ ដូចខាងក្រោម៖

(ក) **កម្មវិធីធម្មតា:** បន្ទាត់ពន្ធគយដែលបានបញ្ចូលនៅក្នុងកម្មវិធីធម្មតា ធ្វើឡើងដោយភាគីនីមួយៗ ដោយខ្លួនឯង ត្រូវមានអត្រាពន្ធគយអនុវត្ត MFN ដែលត្រូវកាត់បន្ថយ ឬលុបបំបាត់ជាបន្តបន្ទាប់រៀងៗខ្លួន ឱ្យស្របទៅតាមបែបបទ ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀងនេះ ក្នុងបំណងដើម្បីសំរេចគោលដៅដូចដែលបានរៀបរាប់នៅក្នុងចំណុចចាប់ផ្តើម ។

(ខ) **កម្មវិធីវិទយិត:** បន្ទាត់ពន្ធគយដែលបានបញ្ចូលនៅក្នុងកម្មវិធីវិទយិត ធ្វើឡើងដោយភាគីនីមួយៗ ដោយខ្លួនឯង ត្រូវមានអត្រាពន្ធគយអនុវត្ត MFN ដែលត្រូវកាត់បន្ថយ ឬលុបបំបាត់ ឱ្យស្របទៅតាមបែបបទដែលមានចែងឧបសម្ព័ន្ធ២ នៃកិច្ចព្រមព្រៀងនេះ ។

៣. ផ្អែកទៅតាមឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃកិច្ចព្រមព្រៀងនេះ រាល់ការសន្យាទាំងអស់ដែលធ្វើឡើងដោយភាគីនីមួយៗ នៅក្រោមមាត្រានេះ ត្រូវតែអនុវត្តដូចៗគ្នា ចំពោះគ្រប់ភាគីទាំងអស់ ។

## មាត្រា៤

## តម្លាភាព

មាត្រា X របស់ GATT 1994 ត្រូវបានដាក់បញ្ចូល និងបង្កើតជាផ្នែកដ៏សំខាន់មួយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៥

## វិធានប្រកបដោយនិតិវិធី ៧

វិធានប្រភពដើមទំនិញ និងនិតិវិធីចេញវិញ្ញាបនប័ត្រ អាចអនុវត្តទៅលើផលិតផលដែលគ្របដណ្តប់នៅក្នុងកិច្ចព្រមព្រៀងនេះ និងក្រោមកម្មវិធីប្រមូលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ៣ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា៦

## ការកែប្រែសម្បទាន

១. ភាគីណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ អាចធ្វើការកែប្រែ ឬដកចេញនូវសម្បទាន ដែលខ្លួនធ្វើបានតាមរយៈការចរចា និងស្រុះស្រួលគ្នាជាមួយភាគីមួយទៀត នៅក្រោមកិច្ចព្រមព្រៀងនេះ ។

២. នៅក្នុងការចរចា និងការព្រមព្រៀងបែបនេះ ដែលអាចរួមបញ្ចូលនូវបញ្ញត្តិសំរាប់ធ្វើការកែប្រែការសងជំងឺចិត្ត ចំពោះផលិតផលនានា ហើយភាគីពាក់ពន្ធ័ត្រូវតែរក្សានូវកំរិតសម្បទានទូទៅ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក មិនតិចជាងពាណិជ្ជកម្មដែលបានផ្តល់ឱ្យ នៅក្នុងកិច្ចព្រមព្រៀងនេះទេ មុនពេលធ្វើការចរចា និងព្រមព្រៀងបែបនេះ ។

## មាត្រា៧

## បទបញ្ញត្តិអង្គការ WTO

១. ចំពោះបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងទាំងឡាយនាអនាគត អាចត្រូវបានភាគីទាំងអស់ព្រមព្រៀងគ្នា ធ្វើការត្រួតពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងនេះ នៅក្រោមមាត្រា ១៧ នៃកិច្ចព្រមព្រៀងនេះ ហើយតាមរយៈនេះ ភាគីទាំងអស់អាចស្រុះស្រួលគ្នា និងអះអាងជាថ្មីនូវការសន្យារបស់ខ្លួន ធ្វើការគោរពទៅតាមបញ្ញត្តិទាំងឡាយនៃច្បាប់របស់អង្គការ WTO នៅក្នុងចំណោមបញ្ហានានា១ ដូចជា វិធានការមិនមែនពន្ធគយ របាំងបច្ចេកទេសពាណិជ្ជកម្ម វិធានការអនាម័យ និងភូតភាមអនាម័យ វិធានការឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងកម្មសិទ្ធបញ្ញាជាដើម ។

២. បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងពហុភាគីរបស់អង្គការ WTO ស្តីពីពាណិជ្ជកម្មទំនិញ ដែលមិនត្រូវបានចែងច្បាស់លាស់នៅក្នុង ឬមិនបានកែប្រែដោយកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តបានចំពោះកិច្ចព្រមព្រៀងនេះ បើពុំមានបរិបទណាតំរូវឱ្យផ្ទុយពីនេះ។

## មាត្រា៨

## ការរឹតត្បិតបរិមាណ និងរបាំងមិនមែនពន្ធគយ ៧

១. ភាគីនីមួយៗមិនត្រូវប្រកាន់នូវការអនុវត្តន៍រឹតត្បិតលើបរិមាណផ្សេងៗនោះទេ ទោះជាពេលណាក៏ដោយ បើពុំដូច្នោះទេ លុះត្រាតែមានការអនុញ្ញាតនៅក្រោមបទបញ្ញត្តិនានារបស់អង្គការ WTO ។

២. ភាគីទាំងអស់ត្រូវតែបង្ហាញនូវរបាំងមិនមែនពន្ធគយរបស់ខ្លួន (ដោយមិនរាប់បញ្ចូលនូវការរឹតត្បិតលើបរិមាណ) ដើម្បីធ្វើការលុបបំបាត់ជាបន្ទាន់ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ ក្របខ័ណ្ឌពេលវេលា សំរាប់ធ្វើការលុបបំបាត់របាំងមិនមែនពន្ធគយទាំងនេះ ត្រូវតែមានការព្រមព្រៀងគ្នាទៅវិញទៅមកពីសំណាក់ភាគីទាំងអស់ ។

៣. គ្រប់ភាគីទាំងអស់ ត្រូវតែផ្តល់ជូន និងធ្វើឱ្យភាគីដទៃៗទៀត ទទួលបាននូវពត៌មានស្តីពីការរឹតត្បិតលើបរិមាណទំនិញរបស់ខ្លួន នៅពេលអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

## មាត្រា៩
## វិធានការការពារ

១. ភាគីនីមួយៗដែលជាសមាជិកនៃអង្គការ WTO រក្សាសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន នៅក្រោមមាត្រា XIX របស់ GATT 1994 និងកិច្ចព្រមព្រៀងរបស់អង្គការ WTO ស្តីពីការការពារ ។

២. ចំពោះវិធានការការពាររបស់ ACFTA ភាគីមួយមានសិទ្ធិនៅក្នុងការចាត់វិធានការបែបនេះ នៅលើផលិតផលមួយ នៅក្នុងរយៈពេលអន្តរកាលមួយសំរាប់ផលិតផលនោះ។ រយៈពេលអន្តរកាលសំរាប់ផលិតផលមួយ នឹងត្រូវចាប់ផ្តើមចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ និងត្រូវបញ្ចប់នៅក្នុងរយៈពេល៥ឆ្នាំ ពីកាលបរិច្ឆេទនៃការបញ្ចប់ការកាត់បន្ថយ និងការលុបបំបាត់ពន្ធគយសំរាប់ផលិតផលនោះ ។

៣. ភាគីមួយសេរីភាពក្នុងការចាត់វិធានការការពាររបស់ ACFTA ប្រសិនបើជាលទ្ធផលមួយនៃកាតព្វកិច្ចដែលបានធ្វើឡើងដោយភាគីនោះ រួមទាំង ការធ្វើសម្បទានផ្នែកពន្ធគយនៅក្រោមកម្មវិធីប្រមូលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬកិច្ចព្រមព្រៀងនេះផង ឬប្រសិនជាលទ្ធផលមួយនៃការអភិវឌ្ឍន៍ ដែលមិនអាចស្មានទុកជាមុនបាន និងជាលទ្ធផលនៃកាតព្វកិច្ចនានាដែលបានធ្វើឡើងដោយភាគីនោះ ដោយរាប់បញ្ចូលទាំងការធ្វើសម្បទានផ្នែកពន្ធគយនៅក្រោមកម្មវិធីប្រមូលផលដើមដៃ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬនៅក្រោមកិច្ចព្រមព្រៀងនេះ ការនាំចូលនៃផលិតផលពិសេសណាមួយពីភាគីផ្សេងៗ ដែលធ្វើឱ្យកើនឡើងនូវបរិមាណនៃផលិតផលបែបនេះ ឬទាក់ទងទៅនឹងផលិតកម្មក្នុងស្រុក ហើយនៅក្នុងលក្ខខ័ណ្ឌបែបនេះ ធ្វើឱ្យប៉ះពាល់ ឬគំរាមកំហែង បង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ដោយសារភាគីនាំចូលផលិតនូវផលិតផលដូចគ្នា ឬផលិតផលដែលមានលក្ខណៈប្រកួតប្រជែងដោយផ្ទាល់ជាមួយនឹងផលិតកម្មក្នុងស្រុក ។

៤. បើសិនជាវិធានការការពារមួយរបស់ ACFTA ត្រូវបានគេអនុវត្ត ភាគីដែលអនុវត្តវិធានការនេះ អាចបង្កើនអត្រាពន្ធគយរបស់គេទៅលើផលិតផលពាក់ព័ន្ធទៅតាមអត្រាពន្ធគយ MFN របស់ WTO ហើយ ត្រូវអនុវត្តទៅលើផលិតផលបែបនេះ នៅពេលណាដែលវិធាននេះបានការចូលជាធរមាន ។

៥. វិធានការការពាររបស់ ACFTA មួយ អាចត្រូវបានគេចាប់ផ្តើមអនុវត្តដំបូងក្នុងរង្វង់រយៈពេល ៣ ឆ្នាំ ហើយអាចត្រូវបានពន្យាមិនលើសពីរយៈពេល១ឆ្នាំឡើយ ។ ថ្វីបើមានរយៈពេលមួយសំរាប់ចាត់វិធានការការពាររបស់ ACFTA ទៅលើផលិតផលមួយក៏ដោយ វិធានការបែបនេះ ត្រូវបានបញ្ឈប់នៅឯទីបញ្ចប់នៃរយៈពេលអន្តរកាលសំរាប់ផលិតផលនោះ ។

៦. នៅក្នុងការអនុវត្តវិធានការការពាររបស់ ACFTA ភាគីនានាត្រូវអនុម័តច្បាប់ផ្សេងៗសំរាប់អនុវត្តវិធានការការពារនេះ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការការពាររបស់អង្គការ WTO ដោយមានការលើកលែងចំពោះវិធានការរិតត្បិតបរិមាណទំនិញ ដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៩ មាត្រា ១៣ និង មាត្រា ១៤ នៃកិច្ចព្រមព្រៀងស្តីពីវិធានការការពាររបស់អង្គការ WTO ។ ដូច្នេះរាល់បញ្ញត្តិទាំងអស់ នៃកិច្ចព្រមព្រៀងស្តីពីវិធានការការពាររបស់អង្គការ WTO ត្រូវដាក់បញ្ចូល និងបង្កើតជាផ្នែកមួយដ៏សំខាន់នៃកិច្ចព្រមព្រៀងនេះ ។

៧. វិធានការការពារមួយរបស់ ACFTA មិនត្រូវអនុវត្តប្រឆាំងទៅនឹងផលិតផលមួយ ដែលមានប្រភពដើមពីភាគីមួយទៀតនោះទេ ឱ្យតែភាគហ៊ុននៃការនាំចូលផលិតផលពាក់ពន្ធ័នោះ ស្ថិតនៅក្រោមភាគីនាំចូលមិនលើសពី ៣%នៃការនាំចូលសរុបរបស់ភាគីទាំងអស់ ។

៨. នៅក្នុងការស្វែងរកនូវសំណងជំងឺចិត្ត នៅក្រោមមាត្រា៨ នៃកិច្ចព្រមព្រៀងរបស់អង្គការ WTO ស្តីពីការការពារ សំរាប់វិធានការការពារមួយរបស់ ACFTA ភាគីនានាត្រូវស្វែងរកគណៈវិនិច្ឆ័យដ៏សមស្របមួយ យោងតាមកថាខ័ណ្ឌទី១២ ដើម្បីធ្វើការកំណត់នូវកំរិតសមភាពនៃការធ្វើសម្បទានមុននឹងធ្វើការពន្យាពេលណាមួយនៃសម្បទានដូចគ្នានោះ ។ បណ្តឹងណាមួយធ្វើឡើងដោយគណៈវិនិច្ឆ័យនេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល៩០ថ្ងៃ ពីកាលបរិច្ឆេទដែលវិធានការការពាររបស់ ACFTA ត្រូវបានអនុវត្ត ។

៩. ការបញ្ឈប់វិធានការការពារ ACFTA របស់ភាគីមួយនៅលើផលិតផលមួយ អត្រាពន្ធគយសំរាប់ផលិតផលនោះ ដោយយោងទៅលើកម្មវិធីកាត់បន្ថយនិងលុបបំបាត់ពន្ធគយរបស់ភាគីនោះ ត្រូវជាអត្រាពន្ធគយ ដែលមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២នៃកិច្ចព្រមព្រៀងនេះ ហើយត្រូវចូលជាធរមានចាប់ពីថ្ងៃទី១ខែមករា នៃឆ្នាំដែលវិធានការការពារនោះត្រូវបានបញ្ចប់ ។

១០. រាល់ការផ្ទេរប្តូរទំនាក់ទំនង និងឯកសារផ្លូវការនៅក្នុងចំណោមភាគីទាំងអស់ និងជាមួយគណៈកម្មាធិការការពារ ដែលពាក់ព័ន្ធទៅនឹងវិធានការការពាររបស់ ACFTA យោងតាមកថាខ័ណ្ឌទី១២ ត្រូវតែធ្វើឡើងលាយល័ក្ខអក្សរ និងជាភាសាអង់គ្លេស ។

១១. នៅពេលធ្វើការអនុវត្តវិធានការការពាររបស់ ACFTA ភាគីមួយមិនត្រូវពឹងផ្អែកដូចគ្នាទាំងស្រុងទៅ នឹងវិធានការការពាររបស់អង្គការ WTO ដោយយោងទៅលើកថាខ័ណ្ឌ១ នោះទេ ។

១២. ចំពោះគោលបំណងនៃមាត្រានេះ ការយោងណាមួយទៅលើ " ក្រុមប្រឹក្សាពាណិជ្ជកម្មទំនិញ " ឬ " គណៈកម្មការការពារ " នៅក្នុងបញ្ញត្តិរួមនៃកិច្ចព្រមព្រៀងអង្គការ WTO ការរង់ចាំការបង្កើតឡើងនូវគណៈកម្មាធិការអចិន្ត្រៃយ៍នៅក្រោមកថាខ័ណ្ឌ១ នៃមាត្រា១៦ នោះត្រូវបានសំដៅទៅលើ AEM-MOFCOM ឬ SEOM-MOFCOM ដែលជាក្រុមប្រឹក្សាសមស្របមួយ ហើយដែលនឹងត្រូវជំនួសដោយគណៈកម្មាធិការ អចិន្ត្រៃយ៍មួយ នៅពេលដែលស្ថាប័ននេះត្រូវបានបង្កើតឡើង។

## មាត្រា១០
## ការបង្កើនល្បឿនការសន្យា

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងភាគីនានាពីការចូលរួមការចរចា និងរៀបចំផែនការដើម្បីបង្កើនល្បឿននៃការអនុវត្តន៍ការសន្យាក្រោមកិច្ចព្រមព្រៀងនេះឡើយ ឲ្យតែការរៀបចំផែនការនេះ ត្រូវបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបានអនុវត្តន៍ដោយភាគីទាំងអស់ ។

## មាត្រា១១
## វិធានការការពារជញ្ជីងទូទាត់

នៅពេលដែលភាគីមួយ ស្ថិតនៅក្នុងវិបត្តិធ្ងន់ធ្ងរផ្នែកជញ្ជីងទូទាត់ និងជួបការលំបាក ឬគំរាមកំហែងផ្នែកហិរញ្ញវត្ថុក្រៅប្រទេស ដោយអនុលោមទៅតាម GATT 1994 និងការយល់យោគគ្នាស្តីពីបញ្ញត្តិនៃជញ្ជីងទូទាត់របស់ GATT 1994 ភាគីនោះ អាចដាក់នូវវិធានការរិតត្បិតលើការនាំចូលបាន ។

## មាត្រា១២
## ការលើកលែងទូទៅ

ផ្អែកតាមតំរូវការ វិធានការបែបនេះ មិនត្រូវបានអនុវត្តក្នុងសភាពដែលអាចបង្កើតជាមធ្យោបាយបំពាបំពានណាមួយ ឬរើសអើងដោយអយុត្តិធម៌ រវាងភាគីដែលស្ថិតនៅក្នុងលក្ខខ័ណ្ឌដូចគ្នា ឬរិតត្បិតលើ

ពាណិជ្ជកម្មអន្តរជាតិដោយលាក់កំបាំងនោះទេ ហើយគ្មានអ្វីឡើយក្នុងកិច្ចព្រមព្រៀងនេះ ដែលត្រូវបានបកស្រាយ ដើម្បីហាមឃាត់ភាគីមួយពីធ្វើការអនុម័ត ឬពង្រឹងការអនុវត្តន៍នូវវិធានការៈ

(ក) ចាំបាច់ដើម្បីការពារសីលធម៌សាធារណៈ

(ខ) ចាំបាច់ដើម្បីការពារ មនុស្ស សត្វ ឬជីវិតរុក្ខជាតិ ឬសុខភាព

(គ) ពាក់ពន្ធ័និងការនាំចូល ឬការនាំចេញ មាស ឬប្រាក់

(ឃ) ចាំបាច់ដើម្បីរក្សាភាពស្របច្បាប់ ឬបញ្ញត្តិនានា ដែលស្របនឹងបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រួមទាំងបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធទៅនឹងការពង្រឹងការអនុវត្តន៍ពន្ធគយ និងការពង្រឹងការអនុវត្តន៍ ទៅលើប្រតិបត្តិការផ្តាច់មុខ នៅក្រោមកថាខ័ណ្ឌទី៤ នៃមាត្រា២ និងមាត្រា ១៧ នៃ GATT 1994 បញ្ញត្តិស្តីពីការការពារប៉ាត់តង់ ពាណិជ្ជសញ្ញា សិទ្ធិនិពន្ធ និងការទប់ស្កាត់អំពើក្លែងបន្លំជាដើម ។

(ង) ពាក់ព័ន្ធទៅនឹងផលិតផលផលិតដោយអ្នកទោស ។

(ច) ដាក់សំរាប់ការពាររតនសម្បត្តិសិល្បៈ និងប្រវត្តិសាស្ត្រជាតិ ឬតម្លៃបុរាណវត្ថុវិទ្យា។

(ឆ) ពាក់ព័ន្ធទៅនឹងការអភិរក្សធនធានធម្មជាតិដែលងាយបាត់បង់ ប៉ុន្តែវិធានការបែបនេះក៏ត្រូវបានអនុវត្តស្របជាមួយនឹងវិធានការរឹតត្បិតលើការផលិត ឬការប្រើប្រាស់ក្នុងស្រុកផងដែរ ។

(ជ) អនុវត្តស្របទៅនឹងកាតព្វកិច្ច នៅក្រោមកិច្ចព្រមព្រៀងទំនិញអន្តររដ្ឋាភិបាលណាមួយ ដែលស្របទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានដាក់ជូនអង្គការ WTO ហើយមិនមានការជំទាស់ ឬភាគីខ្លួនឯងផ្ទាល់ បានដាក់ជូន WTO ហើយមិនមានការជំទាស់លើបញ្ហានេះ ។

(ឈ) ពាក់ព័ន្ធជាមួយនឹងការរឹតត្បិតលើការនាំចេញវត្ថុធាតុដើមក្នុងស្រុក ដែលវាជាការចាំបាច់ដើម្បីធានាឱ្យមានបរិមាណពិសេសសំរាប់វត្ថុធាតុដើមទាំងនោះ សំរាប់ផ្តល់ឱ្យឧស្សាហកម្មផលិតក្នុងស្រុក នៅក្នុងរយៈពេលដែលតំលៃវត្ថុធាតុដើមក្នុងស្រុកទាំងនោះទាបជាងតំលៃវត្ថុធាតុដើមពិភពលោក ដែលជាផ្នែកមួយនៃផែនការស្ថេរភាពតំលៃរបស់រដ្ឋាភិបាល ឱ្យតែការរឹតត្បិតទាំងនេះ មិនត្រូវបានធ្វើឡើង ដើម្បីបង្កើននូវការនាំចេញ ឬផ្តល់នូវការការពារដល់ឧស្សាហកម្មក្នុងស្រុក និងមិនប្រាសចាក ពីបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ដែលទាក់ទិនទៅនឹងការមិនរើសអើង ។

(ញ) ពិសេសសំរាប់ទិញ និងចែកចាយផលិតផលទូទៅ ឬកង្វះខាតនៃការផ្គត់ផ្គង់ក្នុងស្រុក ឱ្យតែវិធានការទាំងនេះស្របទៅនឹងគោលការណ៍ ដែលភាគីទាំងអស់ត្រូវមានសិទ្ធិទទួលចំណែកស្មើៗគ្នាពីការផ្គត់ផ្គង់អន្តរជាតិនៃផលិតផលទាំងនេះ ហើយវិធានការណាដែលមានលក្ខណៈ ៧

មិនស្របទៅនឹងបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានបញ្ឈប់ បន្ទាប់ពីពួកគេទទួលបាននូវបទកំហិតទាំងនេះ ។

## មាត្រា១៣
## ការលើកលែងសំរាប់សន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយៈ

(ក) ដើម្បីតំរូវឱ្យភាគីណាមួយផ្តល់នូវព័ត៌មានដោយបើកចំហ ដែលគេចាត់ទុកថា វាផ្ទុយនឹងផលប្រយោជន៍សន្តិសុខរបស់គេនោះទេ ។

(ខ) ដើម្បីរារាំងភាគីណាមួយពីការចាត់វិធានការ ដែលគេចាត់ទុកថា វាជាការចាំបាច់សំរាប់ការពារផលប្រយោជន៍សន្តិសុខពិសេសរបស់គេនោះទេ ដោយរួមបញ្ចូល ប៉ុន្តែមិនត្រូវបានកំរិតចំពោះៈ

(១) សកម្មភាពពាក់ព័ន្ធនឹងសារធាតុផ្ទុះ ឬវត្ថុដែលទាញចេញពីសារធាតុផ្ទុះទាំងនោះ ។

(២) សកម្មភាពពាក់ព័ន្ធទៅនឹងការធ្វើចរាចរគ្រឿងសព្វាវុធ គ្រាប់រំសេវ និងឧបករណ៍សង្គ្រាមនិងការធ្វើចរាចរបែបនេះ ចំពោះទំនិញ និងបរិក្ខាផ្សេងៗ ដែលបំរើដោយផ្ទាល់ ឬដោយប្រយោល ក្នុងគោលបំណងផ្គត់ផ្គង់ដល់ការបង្កើតកងទ័ព ។

(៣) ការចាត់វិធានការ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដ៏សំខាន់នានា ពីការប៉ុនប៉ង ដើម្បីកាត់ផ្តាច់ ឬធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ។

(៤) ចាត់វិធានក្នុងគ្រាមានសង្គ្រាម ឬគ្រោះអាសន្ននៅក្នុងទំនាក់ទំនងក្នុងស្រុក ឬអន្តរជាតិ ។

(គ) ដើម្បីហាមឃាត់ភាគីណាមួយពីការចាត់វិធានការ ដែលស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិសុខនិងសន្តិភាពអន្តរជាតិនោះឡើយ ។

## មាត្រា១៤
## ការទទួលស្គាល់ឋានៈសេដ្ឋកិច្ចទីផ្សាររបស់ចិន

សមាជិកនីមួយៗ នៃរដ្ឋជាសមាជិករបស់អាស៊ានទាំង១០ បានឯកភាពទទួលស្គាល់ថា ចិនជាប្រទេសមួយមានសេដ្ឋកិច្ចទីផ្សារសេរីពេញលេញ ហើយនឹងមិនត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះតទៅនូវផ្នែកទី១៥ និងផ្នែកទី១៦ នៃពិធីសារសុំចូលអង្គការ WTO របស់សាធារណរដ្ឋប្រជាមានិតចិន និង

កថាខ័ណ្ឌទី ២៤២ នៃរបាយការណ៍របស់ក្រុមការងារស្ដីពីការសុំចូលអង្គការ WTO របស់ចិនផងដែរ ដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម រវាងចិន និងសមាជិកនីមួយៗ នៃរដ្ឋជាសមាជិករបស់អាស៊ានទាំង១០ ។

## មាត្រា១៥
## រដ្ឋ តំបន់ និងរដ្ឋាភិបាលក្នុងស្រុក

ក្នុងការបំពេញកាតព្វកិច្ច និងការសន្យារបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវធានាប្រតិបត្តិតាមអាជ្ញាធរ និងរដ្ឋាភិបាលក្នុងស្រុក និងតំបន់ របស់ភាគីនានា នៅលើទឹកដីដែលខ្លួនតាំងនៅ ក៏ដូចជាប្រតិបត្តិតាមស្ថាប័នក្រៅរដ្ឋាភិបាល (ក្នុងការអនុវត្តន៍សិទ្ធិដែលផ្ដល់ឱ្យដោយរដ្ឋាភិបាល និងអាជ្ញាធរ មជ្ឈឹម រដ្ឋ តំបន់ ឬក្នុងស្រុក) នៅលើទឹកដីដែលខ្លួនតាំងនៅ ។

## មាត្រា១៦
## ការរៀបចំស្ថាប័ន

១. ដោយរង់ចាំកាបង្កើតស្ថាប័នអចិន្ត្រៃយ៍មួយនោះ AEM-MOFCCOM ដែលមានការគាំទ្រ និងជំនួយពី SEOM-MOFCOM នឹងមើលការខុសត្រូវគ្រប់គ្រង សំរបសំរួល និងត្រួតពិនិត្យឡើងវិញលើការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

២. លេខាធិការដ្ឋានអាស៊ាន ត្រូវពិនិត្យមើល និងរាយការណ៍ជូន SEOM-MOFCOM ស្ដីអំពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។ ភាគីទាំអស់ ត្រូវសហការជាមួយលេខាធិការដ្ឋានអាស៊ានក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ។

៣. ភាគីនិមួយៗ ត្រូវចាត់តាំងអ្នកទទួលបន្ទុកទំនាក់ទំនង ដើម្បីសំរួលការទាក់ទងរវាងភាគីនានា អំពីបញ្ហាណាមួយដែលគ្របដណ្ដប់ដោយកិច្ចព្រមព្រៀងនេះ។ នៅពេលមានសំណើពីភាគីមួយ អ្នកទទួលបន្ទុកទំនាក់ទំនងរបស់ភាគីដែលត្រូវបានគេស្នើសុំ ត្រូវប្រាប់គេអំពីការិយាល័យ ឬមន្ត្រីទទួលបន្ទុកលើបញ្ហានោះ ហើយជួយសំរួលក្នុងការទាក់ជាមួយភាគីស្នើសុំផងដែរ។

## មាត្រា១៧
## ការពិនិត្យឡើងវិញ

១. AEM-MOFCCOM ឬតំណាងស្របច្បាប់របស់ខ្លួន ត្រូវជួបគ្នា១ឆ្នាំម្ដង ចាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយបន្ទាប់មកជួបគ្នា២ឆ្នាំម្ដង ឬបើមិនដូច្នោះទេ អាចធ្វើការជួបគ្នាតាមការចាំបាច់ ដើម្បីត្រួតពិនិត្យមើលកិច្ចព្រមព្រៀងនេះឡើងវិញ ក្នុងគោលបំណងរិះរកវិធានការបន្ថែមទៀតក

ដើម្បីធ្វើសេរីនីយកម្មពាណិជ្ជកម្មទំនិញ ព្រមទាំងធ្វើការអភិវឌ្ឍន៍បទបញ្ញត្តិ និងចរចាកិច្ចព្រមព្រៀង លើបញ្ហាផ្សេងៗ ដែលមានចែងក្នុងមាត្រា៧ នៃកិច្ចព្រមព្រៀងនេះ ឬកិច្ចការពាក់ព័ន្ធផ្សេងៗទៀត ដែលអាចឈានទៅស្រុះស្រួលគ្នាបាន ។

២. ភាគីនានាត្រូវយកចិត្តទុកដាក់លើបទពិសោធន៍រៀងខ្លួនៗនៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវធ្វើការត្រួតពិនិត្យឡើងវិញលើកម្មវិធីវេទយិតក្នុងឆ្នាំ២០០៨ ដើម្បីធ្វើការកែលំអលើលក្ខខ័ណ្ឌបើកចំហរទីផ្សារនៃផលិតផលវេទយិត រួមទាំងលទ្ធភាព នៃការកាត់បន្ថយពន្ធគយលើផលិតផលមួយចំនួនបន្ថែមទៀតនៅក្នុងកម្មវិធីវេទយិត និងលក្ខខ័ណ្ឌនានា ដែលភ្ជាប់ទៅលើប្រព្រឹត្តកម្មអត្រាពន្ធគយទៅវិញទៅមកនៃផលិតផល ដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីវេទយិតរបស់ភាគីមួយ ។

## មាត្រា១៨
## ឧបសម្ព័ន្ធនិងលិខិតុបករណ៍អនាគត

កិច្ចព្រមព្រៀងនេះត្រូវរួមបញ្ចូលនូវៈ

(ក) ឧបសម្ព័ន្ធ និងខ្លឹមសារនានា ដែលនឹងបង្កើតបានជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ ។

(ខ) រាល់លិខិតុបករណ៍ច្បាប់អនាគតទាំងអស់ ត្រូវឯកភាពគ្នាធ្វើឱ្យស្របជាមួយកិច្ចព្រមព្រៀងនេះ ។

## មាត្រា១៩
## វិសោធនកម្ម

កិច្ចព្រមព្រៀងនេះអាចត្រូវធ្វើវិសោធនកម្ម ដោយមានការព្រមព្រៀងគ្នាជាលាយល័ក្ខអក្សរទៅវិញទៅមករវាងភាគីទាំងអស់ ។

## មាត្រា២០
## បញ្ញត្តិផ្សេងៗ

វាលែងតែបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ បើពុំដូច្នេះទេ កិច្ចព្រមព្រៀងនេះ ឬវិធានការដែលបានធ្វើឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ នឹងមិនមានឥទ្ធិពលដល់ ឬបំបាត់សិទ្ធិ និងកាតព្វកិច្ចភាគីណាមួយ នៅក្រោមកិច្ចព្រមព្រៀងផ្សេងៗទៀតដែលភាគីនោះមានស្រាប់នោះឡើយ ។

## មាត្រា២១ ៧

## ការដោះស្រាយវិវាទ

កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទ រវាងអាស៊ាន និងចិន នឹងត្រូវបានយកមកអនុវត្តលើកិច្ចព្រមព្រៀងនេះ ។

## មាត្រា២២

## ការតម្កល់ឯកសារ

ចំពោះរដ្ឋជាសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះ នឹងត្រូវបានតំកល់ទុកជាឯកសារ នៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់ នូវច្បាប់ចំលងដែលមានបញ្ជាក់ត្រឹមត្រូវជូនដល់រដ្ឋជាសមាជិកអាស៊ាននីមួយៗ បន្ទាប់ ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ។

## មាត្រា២៣

## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមាន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ តទៅ ។

២. ភាគីទាំងអស់ត្រូវបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួនឱ្យបានមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ដើម្បីចាប់ផ្តើមអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

៣. ចំពោះភាគីណាដែលមិនអាចបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួននៅមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ទេ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនោះ នៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់អនុវត្តនៅលើកាលបរិច្ឆេទដែលភាគីនោះបានបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួនស្រេចបាច់ហើយ ។

៤. ភាគីមួយដែលបានបញ្ចប់បែបបទផ្ទៃក្នុងរបស់ខ្លួន ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះហើយ ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅដល់ភាគីដទៃៗទៀត ដើម្បីជ្រាប ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែលទទួលបានសិទ្ធិប្រទានពេញលេញពីរដ្ឋាភិបាលនៃប្រទេសនីមួយៗ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

**ធ្វើ** នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ PDR ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ជាពីរច្បាប់ ជាភាសាអង់គ្លេស ។ ៧

## ប្រ៊ុយណេដារូសាឡាំ

PEHIN DATO ABDUL RAHMAN TAIB

រដ្ឋមន្ត្រីឧស្សាហកម្ម និងធនធាន

## ព្រះរាជាណាចក្រកម្ពុជា

**ចម ប្រសិទ្ធ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាណិជ្ជកម្ម

## សាធារណរដ្ឋប្រជាមានិតចិន

BO XILAI

រដ្ឋមន្ត្រីពាណិជ្ជកម្ម

## សធារណរដ្ឋឥណ្ឌូណេស៊ី

MARI ELKA PANGESTU

រដ្ឋមន្ត្រីពាណិជ្ជកម្ម

## សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

SOULIVONG DARAVONG

## ម៉ាឡេស៊ី

RAFIDAH AZIZ

រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

## សហភាពមីយ៉ានម៉ា

SOE THA

រដ្ឋមន្ត្រីផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

## សាធារណរដ្ឋហ្វីលីពីន

CESAR V.PURISIMA

រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

## សាធារណរដ្ឋសិង្ហបុរី

LIM HNG KIANG

រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

## រាជាណាចក្រថៃឡង់ដ៍

WATANA MUANGSOOK

រដ្ឋមន្ត្រីពាណិជ្ជកម្ម

## សាធារណរដ្ឋសង្គមនិយមវៀតណាម

TRUONG DINH TUYEN

រដ្ឋមន្ត្រីពាណិជ្ជកម្ម

ឧបសម្ព័ន្ធ១

# បែបបទសំរាប់កាត់បន្ថយនិងលុបបំបាត់ពន្ធគយ ចំពោះបន្ទាត់ពន្ធគយដែលបានដាក់នៅក្នុងកម្មវិធីធម្មតា

១. បន្ទាត់ពន្ធគយដែលភាគីនីមួយៗ បានដាក់ក្នុងកម្មវិធីធម្មតារបស់ខ្លួន ត្រូវមានអត្រាពន្ធគយអនុវត្ត MFN ត្រូវកាត់បន្ថយ និងលុបបំបាត់បន្តិចម្តងៗ យោងទៅតាមកម្មវិធីខាងក្រោម:

## (១) អាស៊ាន៦ និងចិន

| X=អត្រាពន្ធគយអនុវត្ត MFN | អត្រាពន្ធអនុគ្រោះរបស់ ACFTA ( មិនហួសពីថ្ងៃទី១ ខែមករា) | | | |
|---|---|---|---|---|
| | 2005* | 2007 | 2009 | 2010 |
| X≥ 20% | 20 | 12 | 5 | 0 |
| 15% ≤X <20% | 15 | 8 | 5 | 0 |
| 10%≤ X <15% | 10 | 8 | 5 | 0 |
| 5%< X< 10% | 5 | 5 | 0 | 0 |
| X ≤ 5% | មិនប្រែប្រួល | | 0 | 0 |

* កាលបរិច្ឆេទចាប់អនុវត្តន៍ដំបូង នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥ ។

## (២) វៀតណាម

| X=អត្រាពន្ធគយអនុវត្ត MFN | អត្រាពន្ធអនុគ្រោះរបស់ ACFTA ( មិនហួសពីថ្ងៃទី១ ខែមករា) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 2005* | 2006 | 2007 | 2008 | 2009 | 2011 | 2013 | 2015 |
| X≥ 60% | 60 | 50 | 40 | 30 | 25 | 15 | 10 | 0 |
| 45% ≤X <60% | 40 | 35 | 35 | 30 | 25 | 15 | 10 | 0 |
| 35% ≤X <45% | 35 | 30 | 30 | 25 | 20 | 15 | 5 | 0 |
| 30% ≤X <35% | 30 | 25 | 25 | 20 | 17 | 10 | 5 | 0 |
| 25% ≤X <30% | 25 | 20 | 20 | 15 | 15 | 10 | 5 | 0 |
| 20% ≤X <25% | 20 | 20 | 15 | 15 | 15 | 10 | 0-5 | 0 |
| 15% ≤X <20% | 15 | 15 | 10 | 10 | 10 | 5 | 0-5 | 0 |
| 10% ≤X <15% | 10 | 10 | 10 | 10 | 8 | 5 | 0-5 | 0 |
| 7% ≤X <10% | 7 | 7 | 7 | 7 | 5 | 5 | 0-5 | 0 |
| 5% ≤X <7% | 5 | 5 | 5 | 5 | 5 | 5 | 0-5 | 0 |
| X<5% | មិនប្រែប្រួល | | | | | | | 0 |

* កាលបរិច្ឆេទចាប់អនុវត្តន៍ដំបូង នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥ ។

## (៣) កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា

| X=អត្រាពន្ធគយអនុវត្ត MFN | អត្រាពន្ធអនុគ្រោះរបស់ ACFTA (មិនហួសពីថ្ងៃទី១ ខែមករា) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 2005* | 2006 | 2007 | 2008 | 2009 | 2011 | 2013 | 2015 |
| X≥ 60% | 60 | 50 | 40 | 30 | 25 | 15 | 10 | 0 |
| 45% ≤X <60% | 40 | 35 | 35 | 30 | 25 | 15 | 10 | 0 |
| 35% ≤X <45% | 35 | 35 | 30 | 30 | 20 | 15 | 5 | 0 |
| 30% ≤X <35% | 30 | 25 | 25 | 20 | 20 | 10 | 5 | 0 |
| 25% ≤X <30% | 25 | 25 | 25 | 20 | 20 | 10 | 5 | 0 |
| 20% ≤X <25% | 20 | 20 | 15 | 15 | 15 | 10 | 0-5 | 0 |
| 15% ≤X <20% | 15 | 15 | 15 | 15 | 15 | 5 | 0-5 | 0 |
| 10% ≤X <15% | 10 | 10 | 10 | 10 | 8 | 5 | 0-5 | 0 |
| 7% ≤X <10% | 7** | 7** | 7** | 7** | 7** | 5 | 0-5 | 0 |
| 5% ≤X <7% | 5 | 5 | 5 | 5 | 5 | 5 | 0-5 | 0 |
| X<5% | មិនប្រែប្រួល | | | | | | | 0 |

*កាលបរិច្ឆេទចាប់អនុវត្តដំបូង នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥ ។

**មីយ៉ាន់ម៉ាត្រូវបានអនុញ្ញាតឱ្យរក្សាអត្រារបស់ ACFTA មិនលើសពី ៧.៥ % រហូតដល់ ឆ្នាំ២០១០ ។

២. ប្រសិនភាគីមួយដាក់បន្ទាត់ពន្ធគយទៅក្នុងកម្មវិធីធម្មតា ភាគីនោះនឹងទទួលបាននូវសម្បទានពន្ធគយ ដែលភាគីដ៏ទៃទៀតបានធ្វើចំពោះបន្ទាត់ពន្ធគយនោះ ដូចដែលបានបញ្ជាក់ច្បាស់លាស់នៅក្នុង និង បានអនុវត្តស្របតាមកម្មវិធីពាក់ព័ន្ធនានា នៅក្នុងឧបសម្ព័ន្ធ១ ឬឧបសម្ព័ន្ធ២ រួមជាមួយនឹងការសន្យា និងលក្ខខ័ណ្ឌទាំងឡាយដែលមានចែងនៅក្នុងនេះផងដែរ ។ សិទ្ធិនេះ នឹងត្រូវទទួលបាន ឱ្យតែភាគី នោះប្រកាន់ភ្ជាប់នូវការសន្យារបស់ខ្លួនក្នុងការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ លើបន្ទាត់ពន្ធគយ នោះ ។

៣. អត្រាពន្ធគយដែលបានបញ្ជាក់ច្បាស់លាស់នៅក្នុងកម្មវិធីពាក់ព័ន្ធនានា នៅក្នុងកថាខ័ណ្ឌទី១ គ្រាន់តែ ជាការកំណត់កំរិតអត្រាពន្ធគយអនុគ្រោះរបស់ ACFTA ប៉ុណ្ណោះ ដែលអាចធ្វើទៅបាន ដែលត្រូវ អនុវត្ត ដោយភាគីនីមួយៗ ទៅលើបន្ទាត់ពន្ធគយពាក់ព័ន្ធនៅក្នុងឆ្នាំដែលបានកំណត់នៃការអនុវត្តន៍ ហើយនឹងមិនរារាំងភាគីណាមួយ ពីការបង្កើនល្បឿននៃការកាត់បន្ថយ និងលុបបំបាត់ពន្ធគយរបស់ គេ នៅពេលណាក៏ដោយ ឱ្យតែគេមានប្រាថ្នាធ្វើដូច្នេះ ។

៤. បន្ទាត់ពន្ធគយនៅក្នុងកម្មវិធីធម្មតា ដែលមានអត្រាពន្ធគយជាក់លាក់នោះ នឹងត្រូវកាត់បន្ថយរហូត ដល់សូន្យតាមសមាមាត្រ ស្របតាមរយៈពេលកំណត់ដែលមានចែងក្នុងកថាខ័ណ្ឌទី១ នៃឧបសម្ព័ន្ធ នេះ ។

៥. ចំពោះបន្ទាត់ពន្ធគយទាំងអស់ដែលបានដាក់នៅក្នុងកម្មវិធីធម្មតា នៅពេលដែលអត្រាពន្ធគយអនុវត្ត MFN ចុះដល់០% វានៅតែ០%ដដែរ ។ គ្មានភាគីណាមួយត្រូវបានអនុញ្ញាតឱ្យបង្កើនអត្រាពន្ធគយលើបន្ទាត់ពន្ធគយណាមួយឡើយ លើកលែងមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

៦. ជាផ្នែកមួយសំខាន់នៃការសន្យាទាំងឡាយរបស់ខ្លួន ដើម្បីកាត់បន្ថយ និង/ឬ លុបបំបាត់អត្រាពន្ធគយអនុវត្ត MFN ដែលស្របជាមួយនឹងកម្មវិធីពាក់ព័ន្ធនានា និងកថាខ័ណ្ឌទី១ ភាគីនីមួយៗ សន្យាធ្វើការកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយបន្ថែមទៀត ស្របជាមួយនឹងចំណុចផ្តើមដូចខាងក្រោមនេះ :

**(ក) អាស៊ាន៦ និងចិន**

(១) ភាគីនីមួយៗត្រូវតែកាត់បន្ថយឱ្យនៅត្រឹម ០-៥% នូវអត្រាពន្ធគយយ៉ាងតិច ៤០% ចំពោះបន្ទាត់ពន្ធគយរបស់ខ្លួនដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពីថ្ងៃទី១ ខែកក្កដាឆ្នាំ ២០០៥ ។

(២) ភាគីនីមួយៗត្រូវតែកាត់បន្ថយឱ្យនៅត្រឹម០-៥% នូវអត្រាពន្ធគយយ៉ាងតិច ៦០% ចំពោះបន្ទាត់ពន្ធគយរបស់ខ្លួនដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពី ថ្ងៃទី១ ខែមករា ឆ្នាំ ២០០៧ ។

(៣) ភាគីនីមួយៗ ត្រូវតែលុបបំបាត់ពន្ធគយរបស់ខ្លួនទាំងស្រុង ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ ប៉ុន្តែផ្តល់ភាពទន់ភ្លន់ឱ្យមានបន្សល់ទុកពន្ធគយខ្លះ នៅលើបន្ទាត់ពន្ធគយមួយចំនួន តែមិនឱ្យលើសពី ១៥០ បន្ទាត់ពន្ធគយទេ ដែលត្រូវលុបបំបាត់រហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០១២ ។

(៤) ភាគីនីមួយៗ ត្រូវលុបបំបាត់ពន្ធគយទាំងអស់របស់ខ្លួន ចំពោះបន្ទាត់ពន្ធគយដែលបានបញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១២ ។

**(ខ) រដ្ឋជាសមាជិកអាស៊ានថ្មី**

(១) ភាគីនីមួយៗត្រូវតែកាត់បន្ថយឱ្យនៅត្រឹម០-៥% នូវអត្រាពន្ធគយយ៉ាងតិច៥០% ចំពោះ បន្ទាត់ពន្ធគយរបស់ខ្លួនដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពីថ្ងៃទី១ ខែ មករា ឆ្នាំ២០០៩ សំរាប់វៀតណាម ថ្ងៃទី១ ខែមករា ឆ្នាំ២០១០ សំរាប់ឡាវ PDR និងមីយ៉ាន់ម៉ា និងថ្ងៃទី១ ខែមករា ឆ្នាំ២០១២ សំរាប់កម្ពុជា ។

(២) កម្ពុជា ឡាវ PDR និងមីយ៉ាន់ម៉ា ត្រូវលុបបំបាត់ពន្ធគយរបស់ខ្លួនចំនួន ៤០% ចំពោះ បន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតាមិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៣។

(៣) ចំពោះវៀតណាម ភាគរយចំពោះបន្ទាត់ពន្ធគយក្នុងកម្មវិធីធម្មតា ដែលមានអត្រាពន្ធគយ ដែលត្រូវលុបបំបាត់មិនហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ នោះ ត្រូវតែធ្វើសេចក្តីសំរេចមិនឱ្យ ហួសពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤ ឡើយ ។

(៤) ភាគីនីមួយៗ ត្រូវតែលុបបំបាត់ពន្ធគយរបស់ខ្លួនទាំងស្រុង ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីធម្មតា មិនឱ្យហួសពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៥ ដោយផ្តល់ភាពទន់ភ្លន់ឱ្យមានពន្ធគយខ្លះ នៅលើបន្ទាត់ពន្ធគយមួយចំនួន តែមិនឱ្យលើសពី ២៥០ បន្ទាត់ពន្ធគយទេ ដែលត្រូវលុបបំបាត់រហូតដល់ថ្ងៃទី១ ខែមករាឆ្នាំ ២០១៨។

(៥) ភាគីនីមួយៗត្រូវលុបបំបាត់ពន្ធគយទាំងអស់របស់ខ្លួន ចំពោះបន្ទាត់ពន្ធគយដែលបានបញ្ចូលនៅក្នុងកម្មវិធីធម្មតាមិនឱ្យហួសពីថ្ងៃទី១ ខែមករាឆ្នាំ២០១៨ ឡើយ។

៧. បន្ទាត់ពន្ធគយដែលភាគីទាំងអស់ចុះបញ្ជីក្នុងសេចក្តីបន្ថែម១ នឹងត្រូវធ្វើការលុបបំបាត់ពន្ធគយនៅក្នុង ACFTA របស់ពួកគេរៀងៗខ្លួន មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១២ សំរាប់អាស៊ាន៦ និងចិន និងថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ សំរាប់កម្ពុជា ឡាវ ភូមា និងវៀតណាម (CLMV) ។

# បែបបទសម្រាប់ការកាត់បន្ថយ និងលុបបំបាត់ពន្ធគយ នៃបន្ទាត់ពន្ធគយក្នុងកម្មវិធីរសើបរសើយិតភាព

១. ចំនួនបន្ទាត់ពន្ធគយដែលភាគីនីមួយៗ អាចដាក់បញ្ចូលទៅក្នុងកម្មវិធីរសើបយិត ត្រូវមានមានកំរិតអតិបរមាៈ

**(១) អាស៊ាន៦ និងចិន**

មានចំនួន ៤០០ បន្ទាត់ពន្ធគយនៅក្នុងកំរិត លេខកូដ HS-6ខ្ទង់ (HS-6 digit) និងចំនួន១០%នៃតំលៃនាំចូលសរុប យោងតាមស្ថិតិពាណិជ្ជកម្មឆ្នាំ២០០១។

**(២) កម្ពុជា ឡាវ PDR និងមីយ៉ានម៉ា**

មានចំនួន ៥០០ បន្ទាត់ពន្ធគយក្នុងកំរិតលេខកូដ HS-6ខ្ទង់។

**(៣) វៀតណាម**

មានចំនួន ៥០០ បន្ទាត់ពន្ធគយ នៅក្នុងកំរិតលេខកូដ HS-6ខ្ទង់ និងកំរិតអតិបរមានៃតំលៃនៃការនាំចេញនឹងត្រូវធ្វើសេចក្តីសំរេចមិនឱ្យហួសពីថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៤។

២. បន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលដោយភាគីនីមួយៗ នៅក្នុងកម្មវិធីរសើបយិត នឹងត្រូវធ្វើចំណាត់ថ្នាក់បញ្ចូលនៅក្នុងបញ្ជីរសើបយិត និងបញ្ជីរសើបយិតខ្លាំង។ ទោះជាយ៉ាងនោះក្តី បន្ទាត់ពន្ធគយដែលដាក់បញ្ចូលដោយភាគីនីមួយៗ ទៅក្នុងបញ្ជីរសើបយិតខ្លាំង នឹងត្រូវផ្អែកទៅលើកំរិតអតិបរមាដូចខាងក្រោមៈ

**(១) អាស៊ាន៦ និងចិន**

មិនឱ្យមានចំនួនលើសពី ៤០% នៃចំនួនបន្ទាត់ពន្ធគយសរុប នៅក្នុងកម្មវិធីរសើបយិត ឬចំនួន១០០ បន្ទាត់ពន្ធគយនៅក្នុងកំរិត HS-6ខ្ទង់។ អ្វីក៏ដោយត្រូវមានកំរិតទាបជាងនេះ។

**(២) កម្ពុជា ឡាវ PDR និងមីយ៉ាន់ម៉ា**

មិនឱ្យមានចំនួនលើសពី ៤០% នៃចំនួនបន្ទាត់ពន្ធគយសរុប នៅក្នុងកម្មរសើបយិត ឬចំនួន ១៥០ បន្ទាត់ពន្ធគយនៅក្នុងកំរិត HS-6ខ្ទង់។ អ្វីក៏ដោយត្រូវមានកំរិតទាបជាងនេះ។

**(៣) វៀតណាម**

នឹងត្រូវធ្វើសេចក្តីសំរេចចិត្តមិនឱ្យហួសពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤។

៣. ភាគីទាំងអស់ត្រូវកាត់បន្ថយ និងលុបបំបាត់ពន្ធគយនៅពេលដែលអាចធ្វើបាននូវអត្រាពន្ធគយអនុវត្ត MFN ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីរសើយិត យោងតាមកម្មវិធីដូចខាងក្រោម៖

(១) **អាស៊ាន៦ និងចិន** ត្រូវកាត់បន្ថយអត្រាពន្ធគយអនុវត្ត MFN នៃបន្ទាត់ពន្ធគយ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីរសើយិតរបស់ខ្លួនចំនួន ២០% មិនឱ្យហួសពីថ្ងៃទី១ ខែមករាឆ្នាំ ២០១២។ អត្រាពន្ធគយទាំងនេះ នឹងត្រូវកាត់បន្ថយជាបន្តបន្ទាប់រហូតដល់ ០-៥% មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។

(២) **កម្ពុជា ឡាវ PDR និងមីយ៉ាន់មា** ត្រូវកាត់បន្ថយអត្រាពន្ធគយអនុវត្ត MFN ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីរសើយិតរបស់ខ្លួនចំនួន ២០% មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៥។ អត្រាពន្ធគយទាំងនេះ នឹងត្រូវកាត់បន្ថយជាបន្តបន្ទាប់រហូត ដល់ ០-៥% មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

**វៀតណាម** ត្រូវកាត់បន្ថយអត្រាពន្ធគយអនុវត្ត MFN ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីរសើយិតរបស់ខ្លួន មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ នូវអត្រាមួយ ដែលនឹងត្រូវធ្វើសេចក្តីសំរេច មិនឱ្យហួសពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤។ អត្រាពន្ធគយទាំងនេះ នឹងត្រូវកាត់បន្ថយជាបន្តបន្ទាប់រហូតដល់ ០-៥% មិនហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០។

(៣) **ភាគីទាំងអស់** ត្រូវកាត់បន្ថយអត្រាពន្ធគយអនុវត្ត MFN ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីរសើយិតខ្លាំងរបស់ខ្លួន មិនលើសពី ៥០% មិនឱ្យហួសពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ សំរាប់អាស៊ាន៦ និងចិន និងថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ សំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី។

៤. បន្ទាត់ពន្ធគយនៅក្នុងកម្មវិធីរសើយិត ដែលមានអត្រាពន្ធជាក់លាក់ នឹងត្រូវមានការកាត់បន្ថយពន្ធគយទៅតាមរយៈពេលកំណត់ដែលចែងនៅក្នុងកថាខ័ណ្ឌទី៣ នៃឧបសម្ព័ន្ធនេះ។ សមាមាត្រនៃការកាត់បន្ថយពន្ធចំពោះបន្ទាត់ពន្ធគយទាំងនេះ ត្រូវស្មើនឹងកំរិតមធ្យមភាគនៃការកាត់បន្ថយពន្ធគយតាមតំលៃអត្រាពន្ធគយនៅក្រោមកម្មវិធីរសើយិត ដែលត្រូវមានការកាត់បន្ថយពន្ធគយនៅក្នុងឆ្នាំតែមួយ។

៥. ថ្វីបើមានកម្មវិធីនានានៅក្នុងកថាខ័ណ្ឌទី៣ក្តី ភាគីមួយអាចធ្វើការពន្លឿនដោយឯកតោភាគីនូវការកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយចំពោះបន្ទាត់ពន្ធគយ ដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីរសើយិតនៅពេលណាក៏បាន ឱ្យតែភាគីនោះមានបំណងធ្វើដូច្នេះ។ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀង នេះ

រារាំងភាគីណាមួយមិនឱ្យធ្វើការបង្វែដោយឯកតោភាគីនូវបន្ទាត់ពន្ធគយណាមួយ ពីកម្មវិធីវេទយិត ចូលទៅក្នុងកម្មវិធីធម្មតាឡើយ ឱ្យតែភាគីនោះមានបំណងធ្វើដូច្នេះ។

៦. ប្រព្រឹត្តកម្មអត្រាពន្ធគយទៅវិញទៅមក ចំពោះបន្ទាត់ពន្ធគយដែលបានដាក់បញ្ចូលទៅក្នុងកម្មវិធីវេទយិតដោយភាគីមួយ នឹងត្រូវស្ថិតនៅក្រោមលក្ខខ័ណ្ឌនានាដូចខាងក្រោម:

(១) អត្រាពន្ធគយចំពោះបន្ទាត់ពន្ធគយមួយ ដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីវេទយិតដោយភាគីមួយ ត្រូវតែមានអត្រា ១០% ឬក្រោមនេះ ដើម្បីផ្តល់ឱ្យភាគីនោះទទួលបាននូវប្រព្រឹត្តកម្មទៅវិញទៅមក។

(២) អត្រាពន្ធគយទៅវិញទៅមក នឹងត្រូវអនុវត្តចំពោះបន្ទាត់ពន្ធគយមួយ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីវេទយិតដោយភាគីមួយ នឹងត្រូវជាអត្រាពន្ធគយនៃបន្ទាត់ពន្ធគយរបស់ភាគីនោះផង ឬអត្រាពន្ធគយនៅក្នុងកម្មវិធីធម្មតា នៃបន្ទាត់ពន្ធគយដូចគ្នា របស់ភាគីមួយទៀត ឬរបស់ភាគីដែលស្វែងរកអត្រាពន្ធគយទៅវិញទៅមក តែអ្វីក៏ដោយគឺមានកំរិតខ្ពស់ជាង។

(៣) អត្រាពន្ធគយទៅវិញទៅមក នឹងត្រូវអនុវត្តចំពោះបន្ទាត់ពន្ធគយមួយ ដែលត្រូវបានដាក់បញ្ចូលដោយភាគីមួយនៅក្នុងកម្មវិធីវេទយិត នឹងមិនត្រូវឱ្យលើសពីអត្រាអនុវត្ត MFN នៃបន្ទាត់ពន្ធគយដូចគ្នារបស់ភាគីនោះ ឬភាគីដែលស្វែងរកនូវអត្រាពន្ធគយទៅវិញទៅមកនោះឡើយ។

៧. ប្រព្រឹត្តកម្មលើបន្ទាត់ពន្ធគយរបស់ភាគីទាំងអស់ ត្រូវផ្អែកលើអត្រាក្នុងកូតា និងក្រៅកូតា រួមទាំងបែបបទសំរាប់ធ្វើការកាត់បន្ថយ / លុបបំបាត់ពន្ធគយ នឹងត្រូវធ្វើការពិភាក្សា និងព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីទាំងអស់ មិនហួសពីថ្ងៃទី៣១ ខែមីនា ឆ្នាំ០០៥។ ការពិភាក្សានឹងត្រូវរួមបញ្ចូល ប៉ុន្តែបានកំរិត ចំពោះអត្រាក្នុងកូតា និងក្រៅកូតាទេ។

៨. បន្ទាត់ពន្ធគយដែលចុះបញ្ជីនៅក្នុងបញ្ជីវេទយិត និងបញ្ជីវេទយិតខ្លាំង ដោយភាគីនីមួយៗ នៅក្រោមកម្មវិធីវេទយិត ត្រូវបានចែងនៅក្នុងសេចក្តីបន្ថែមទី១ និងសេចក្តីបន្ថែមទី២ នៃឧបសម្ព័ន្ធនេះ។៧

...ដ្ឋាន សេវា និងបច្ចេកទេស
...កដ្ឋានស្រាវជ្រាវច្បាប់
លេខ ......៥៨៣......
ថ្ងៃទី៣១.០៧.០៨...
...ជូនទៅ ......

# កិច្ចព្រមព្រៀង
# ស្តីពី
# យន្តការដោះស្រាយវិវាទ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការ សេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន

**រដ្ឋា**ភិបាលនៃប្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រ ថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍( អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន រួមគ្នាហៅថាបណ្តាភាគី ប្រទេសសមាជិកអាស៊ាន ឬប្រទេសចិននីមួយៗហៅថាភាគី

**យោង** កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ( កិច្ចព្រមព្រៀងក្របខ័ណ្ឌ) រវាងអាស៊ាន និងប្រទេសចិនចុះហត្ថលេខាដោយប្រមុខរដ្ឋាភិបាល ប្រមុខរដ្ឋនៃប្រទេសសមាជិកអាស៊ាន និងប្រទេសចិននៅភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០០២

**យោង** កថាខ័ណ្ឌ ៧ នៃប្រការ ១១ របស់កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការបង្កើតនីតិវិធីដោះស្រាយវិវាទផ្លូវការសមស្របសំរាប់គោលបំណងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ១ឆ្នាំ ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ ÷

## ប្រការ ១
## និយមន័យ

សំរាប់កិច្ចព្រមព្រៀងនេះ និយមន័យដូចខាងក្រោមនេះនឹងត្រូវបានប្រើប្រាស់លើកលែងតែកាលៈទេសៈតម្រូវផ្សេងពីនេះ ÷ W

ក- និយមន័យទាំងអស់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះនឹងត្រូវប្រើប្រាស់សំរាប់កិច្ចព្រមព្រៀងនេះ

ខ- ថ្ងៃមានន័យថា ថ្ងៃនៃប្រតិទិនរាប់បញ្ចូលទាំងបំណាច់សប្តាហ៍ និងថ្ងៃបុណ្យ

គ- បណ្តាភាគីនៃវិវាទណាមួយ បណ្តាភាគីនៃវិវាទជាក់លាក់ណាមួយ ឬបណ្តាភាគីពាក់ព័ន្ធមានន័យថាភាគីតវ៉ា និងភាគីត្រូវបានតវ៉ា

ឃ- ភាគីតវ៉ាមានន័យថា ភាគីនិងបណ្តាភាគីណាមួយដែលសំណូមពរការពិគ្រោះក្រោមប្រការ៤

ង- ភាគីត្រូវបានតវ៉ាមានន័យថា ភាគីណាមួយដែលសំណូមពរសុំការពិគ្រោះត្រូវបានបញ្ជូនទៅអោយក្រោមប្រការ៤

## ប្រការ ២
## គ្របខ័ណ្ឌ និងការរាប់បញ្ចូល

១. កិច្ចព្រមព្រៀងនេះនឹងអនុវត្តទៅលើវិវាទដែលកើតឡើង ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលនឹងរាប់បញ្ចូលផងដែរនូវឧបសម្ព័ន្ធ និងផ្នែកដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ។ តទៅមុខទៀតការយោងណាមួយទៅដល់កិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងរាប់បញ្ចូលឯកសារស្របច្បាប់ទាំងអស់ដែលបានឯកភាពគ្នាអនុលោមតាមកិច្ចព្រមព្រៀងនេះលើកលែងតែកាលៈទេសៈចែងផ្សេងពីនេះ។

២. វិធាន និងនីតិវិធីនៃការដោះស្រាយវិវាទបន្ថែម ឬពិសេសណាមួយដែលមាននៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះត្រូវបានអនុញ្ញាតអោយរៀបចំជាបញ្ជីតាមការចាត់ការរបស់លេខាធិការដ្ឋានអាស៊ានជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះដោយមានការឯកភាពនៃបណ្តាភាគី។

៣. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌឬដូចដែលបណ្តាភាគីអាចឯកភាពគ្នាផ្សេងពីនេះ បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តចំពោះការជៀសវាង ឬដំណោះស្រាយវិវាទរវាង ឬក្នុងចំណោមបណ្តាភាគីអំពីសិទ្ធិ និងកាតព្វកិច្ចរៀង១ខ្លួនក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

៤. បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះត្រូវបានអនុញ្ញាតអោយប្រើប្រាស់ចំពោះវិធានការដែលប៉ះពាល់ដល់ការគោរពកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលបានចាត់ដោយរដ្ឋាភិបាលកណ្តាល តំបន់ ឬមូលដ្ឋាននៅក្នុងដែនដីនៃភាគី។

៥. ក្រោមលក្ខខណ្ឌនៃកថាខ័ណ្ឌ ៦ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងអាចធ្វើអោយខូចខាតសិទ្ធិណាមួយរបស់បណ្តាភាគីដើម្បីដំណើរការនីតិវិធីដោះស្រាយវិវាទ ដែលអាចរកបានក្រោមសិទ្ធិសញ្ញាណាមួយផ្សេងទៀតដែលបណ្តាភាគីបានចូលរួម ។

៦. នៅពេលដែលគេចាប់ផ្តើមបណ្តឹងដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះឬក្រោមសិទ្ធិសញ្ញាផ្សេងណាមួយទៀតដែលបណ្តាភាគីជម្លោះបានចូលរួមអំពីសិទ្ធិ ឬកាតព្វកិច្ចពិសេសនៃបណ្តាភាគីទាំងអស់ដែលកើតមានឡើងក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌមានសិទ្ធិសញ្ញាផ្សេងទៀត វេទិកាដែលបានជ្រើសរើសដោយភាគីតវ៉ា និងត្រូវប្រើប្រាស់ ។

៧. កថាខ័ណ្ឌទី ៥ និងទី ៦ ខាងលើ នឹងមិនអនុវត្តទេនៅទីណាដែលបណ្តាភាគីនៃវិវាទឯកភាពយ៉ាងជាក់លាក់ទៅលើការប្រើប្រាស់វេទិកាដោះស្រាយវិវាទច្រើនជាងមួយចំពោះវិវាទពិសេសនោះ ។

៨. សំរាប់គោលបំណងនៃកថាខ័ណ្ឌទី ៥ ដល់ទី ៧ ភាគីតវ៉ានឹងត្រូវបានចាត់ទុកថាបានជ្រើសរើសវេទិកាណាមួយហើយនៅពេលដែលភាគីនោះបានសំណូមពរការបង្កើត ឬបញ្ជូនវិវាទទៅអោយក្រុមដោះស្រាយវិវាទ ឬសាលាក្តីអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងណាមួយផ្សេងទៀតដែលបណ្តាភាគីវិវាទបានចូលរួម ។

## ប្រការ ៣
## ការិយាល័យទំនាក់ទំនង

១. សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវ ៖

ក- ចាត់អង្គភាពដែលទទួលខុសត្រូវកិច្ចការទំនាក់ទំនងដែលមានចែងនៅកិច្ចព្រមព្រៀងនេះ

ខ- ទទួលខុសត្រូវចំពោះប្រតិបត្តិការ និងតម្លៃដំណើរការនៃអង្គភាពដែលបានចាត់នេះ

គ- ជូនពត៌មានទៅបណ្តាភាគីនូវទីតាំង និងអាស័យដ្ឋាននៃអង្គភាពដែលបានចាត់ក្នុងរយៈពេល ៣០ថ្ងៃក្រោយការបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

២. លើកលែងតែមានចែងផ្សេងពីកិច្ចព្រមព្រៀងនេះ ការបញ្ជូនសំណូមពរ ឬឯកសារណាមួយក្រោមកិច្ចព្រមព្រៀងនេះ៚

ទៅឱ្យអង្គភាពដែលបានចាត់ពីភាគីណាមួយ ត្រូវបានចាត់ទុកថាជាការបញ្ជូនសំណូមពរ ឬឯកសារនោះទៅឱ្យភាគីនេះ។

## ប្រការ ៤

## ការពិគ្រោះ

១. ភាគីត្រូវបានតវ៉ាត្រូវផ្តល់ការពិចារណាដ៏សមរម្យ និងឱកាសគ្រប់គ្រាន់សំរាប់ការពិគ្រោះចំពោះសំណូមពរពិគ្រោះដែលបានលើកឡើងដោយភាគីតវ៉ាអំពីបញ្ហាអ្វីមួយដែលអាចប៉ះពាល់ដល់ការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយតាមរយៈនោះ៖

ក- ផលប្រយោជន៍ណាមួយរបស់ភាគីតវ៉ាក្រោមកិច្ចព្រមព្រៀងនេះត្រូវបានទុកជាមោឃៈ ឬបន្ថយ

ខ- ការសំរេចទិសដៅណាមួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវបានបង្អាក់ជាលទ្ធផលនៃការខកខានមិនបានបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌដោយភាគីត្រូវបានតវ៉ា។

២. សំណូមពរណាមួយសំរាប់ការពិគ្រោះ នឹងត្រូវស្នើឡើងជាលាយល័ក្ខអក្សរដែលត្រូវមានចែងជាវិធានការជាក់លាក់ចំពោះបញ្ហា និងមូលដ្ឋានច្បាប់ស្របទៅតាមការពិត (រាប់បញ្ចូលទាំងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលត្រូវចោទបានរំលោភ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត) នៃការតវ៉ា។ ភាគីតវ៉ាត្រូវបញ្ជូនសំណូមពរទៅអោយភាគីត្រូវបានតវ៉ាហើយ និងបណ្តាភាគីដែលនៅសល់។ នៅពេលបានទទួលភាគីត្រូវបានតវ៉ាត្រូវប្រាប់អោយដឹងពីការបានទទួលសំណូមពរនេះទៅភាគីតវ៉ា និងបណ្តាភាគីនៅសល់ព្រមពេលជាមួយគ្នានេះ។

៣. បើសិនជាសំណូមពរពិគ្រោះត្រូវបានធ្វើឡើង ភាគីត្រូវបានតវ៉ាត្រូវឆ្លើយទៅនឹងសំណូមពរនេះក្នុងរយៈ ពេល៧ថ្ងៃក្រោយកាលបរិច្ឆេទនៃការទទួល ហើយត្រូវចាប់ផ្តើមការពិគ្រោះដោយស្មោះត្រង់ក្នុងរយៈពេល មិនលើសពី ៣០ ថ្ងៃក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរ ដើម្បីឈានទៅរកដំណោះស្រាយមួយដែលពេញចិត្តទៅវិញទៅមក។ បើសិនជាភាគីត្រូវបានតវ៉ាមិនឆ្លើយតបក្នុងរយៈពេល ៧ ថ្ងៃដូចចែងខាងលើ ឬមិនចាប់ផ្តើមពិគ្រោះក្នុងរយៈពេល ៣០ ថ្ងៃដូចចែងខាងលើ ភាគីតវ៉ាអាចបន្តធ្វើដោយត្រង់ទៅរកសំណើចាត់តាំងសាលាក្តីជំនុំជំរះក្រោមប្រការ ៦។

៤. បណ្តាភាគីវិវាទត្រូវខិតខំដើម្បីឈានដល់ដំណោះស្រាយពេញចិត្តទៅវិញទៅមកនៃបញ្ហាណាក៏ដោយតាមរយៈការពិគ្រោះ។ ចំពោះបញ្ហានេះបណ្តាភាគីពាក់ព័ន្ធត្រូវ៖

ក- ផ្តល់ពត៌មានគ្រប់គ្រាន់ដើម្បីជួយដល់ការពិនិត្យពេញលេញអោយដឹងពីវិធានការ ដែលអាចប៉ះពាល់ដល់៧

ប្រតិបត្តិការ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

ខ- ចាត់ទុកជាការសម្ងាត់នូវពត៌មានណាមួយដែលបានផ្លាស់ប្ដូរនៅពេលពិគ្រោះ ដែលភាគីពាក់ព័ន្ធផ្សេងទៀត ចាត់ទុកជាការសម្ងាត់

៥. ការពិគ្រោះជាការសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយក្នុងបណ្ដឹងផ្សេងទៀត ឬបណ្ដឹងបន្តណាមួយ។

៦. កាលណាភាគី (ក្រៅពីបណ្ដាភាគីវិវាទ) យល់ថាគេមានផលប្រយោជន៍ច្រើនក្នុងការពិគ្រោះដែលកំពុងដំណើរការអនុលោមតាមមាត្រានេះ ភាគីនោះអាចជូនពត៌មានទៅបណ្ដាភាគីវិវាទជាលាយល័ក្ខអក្សរអំពីបំណងរបស់ខ្លួនចូលរួមការពិគ្រោះក្នុងរយៈពេល ១០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរពិគ្រោះដោយភាគីដែលបានតវ៉ា។ ភាគីនោះអាចចូលរួមការពិគ្រោះបានអោយតែភាគីត្រូវបានតវ៉ាយល់ព្រមថា ការអះអាងថាមានផលប្រយោជន៍ដ៏ច្រើនមានមូលដ្ឋានច្បាស់លាស់។ ភាគីត្រូវបានតវ៉ាត្រូវជូនពត៌មានទៅអោយភាគីតវ៉ា និងបណ្ដាភាគីនៅសល់អំពីការសំរេចរបស់ខ្លួនមុនការចាប់ផ្ដើមការពិគ្រោះ។ ប្រសិនបើជាសំណូមពរសុំចូលរួមការពិគ្រោះត្រូវបានបដិសេធ ភាគីស្នើសុំអាចសំណូមពរការពិគ្រោះដាច់ដោយឡែកក្រោមប្រការនេះ។

៧. ក្នុងករណីបន្ទាន់រាប់បញ្ចូលទាំងករណីដែលពាក់ព័ន្ធដល់ផលិតផលឆាប់ស្អុយរលួយ បណ្ដាភាគីពាក់ព័ន្ធត្រូវចាប់ផ្ដើមពិគ្រោះក្នុងរយៈពេលមិនលើសពី ១០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរដោយភាគីត្រូវបានតវ៉ា។ បើសិនជាការពិគ្រោះខកខានមិនបានដោះស្រាយវិវាទក្នុងរយៈពេល ២០ថ្ងៃ ក្រោយកាលបរិច្ឆេទទទួលសំណូមពរដោយភាគីត្រូវបានតវ៉ាភាគីតវ៉ាអាចបន្តធ្វើដោយត្រង់ទៅរកការបង្កើតសាលាក្ដីក្រោមប្រការ ៦។

៨. ក្នុងករណីបន្ទាន់ រាប់បញ្ចូលទាំងករណីនៃផលិតផលឆាប់ស្អុយរលួយ បណ្ដាភាគីនៃវិវាទ និងសាលាក្ដីត្រូវធ្វើការប្រឹងប្រែងពន្លឿនបណ្ដឹងអោយបានលឿនបំផុត។

## ប្រការ ៥
## ការស្រុះស្រួល និង ការសម្រុះសម្រួល

១. បណ្តាភាគីវិវាទអាចឯកភាពគ្នាលើការស្រុះស្រួល ឬការសម្រុះសម្រួលនៅពេលណាមួយ។ គេអាចចាប់ផ្តើមនៅពេលណាមួយហើយបញ្ចប់ដោយបណ្តាភាគីពាក់ព័ន្ធនៅពេលណាមួយក៏បាន។

២. ប្រសិនបើបណ្តាភាគីនៃវិវាទឯកភាពទម្រង់ការនៃការស្រុះស្រួល ឬការសម្រុះសម្រួលអាចបន្តនៅចំពោះមុខបុគ្គលណាម្នាក់តាមបណ្តាភាគីវិវាទឯកភាពគ្នា ចំណែកឯវិវាទបន្តទៅទៀតសំរាប់ដំណោះស្រាយនៅចំពោះមុខសាលាក្តីដែលចាត់តាំងក្រោមប្រការ ៦។

៣. ទម្រង់ការនៃការស្រុះស្រួល និងសម្រុះសម្រួល និងជំហរប្រកាន់យកដោយបណ្តាភាគីវិវាទក្នុងរយៈពេលបណ្តឹងត្រូវតែជាការសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិនៃភាគីណាមួយក្នុងទម្រង់ការបន្ត ឬផ្សេងទៀត។

## ប្រការ ៦
## ការចាត់តាំងសាលាក្តី

១. បើសិនជាការពិគ្រោះដូចបានចែងក្នុងប្រការ៤ ខកខានមិនបានដោះស្រាយវិវាទក្នុងរយៈពេល ៦០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរសំរាប់ការពិគ្រោះ ឬក្នុងរយៈពេល ២០ថ្ងៃ ក្រោយកាលបរិច្ឆេទខាងលើក្នុងករណីបន្ទាន់រាប់បញ្ចូលទាំងករណីទំនិញងាយស្រួលរលួយ ភាគីតវ៉ាអាចលើកសំណូមពរជាលាយល័ក្ខអក្សរទៅភាគីដែលត្រូវបានតវ៉ាដើម្បីចាត់តាំងសាលាក្តីក្រោមប្រការនេះ។ ច្បាប់ចម្លងនៃសំណូមពរនេះត្រូវធ្វើផងដែរទៅបណ្តាភាគីដែលនៅសល់។

២. សំណូមពរអោយចាត់តាំងសាលាក្តីត្រូវផ្តល់មូលហេតុរាប់បញ្ចូលទាំងអត្តសញ្ញាណកម្មនៃ÷

ក-វិធានការជាក់លាក់ចំពោះបញ្ហា

ខ-មូលដ្ឋានច្បាប់ និងដែលស្របទៅតាមការពិត (រាប់បញ្ចូលទាំងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលត្រូវបានចោទថាបានបំពាន ឬបទបញ្ញត្តិពាក់ពន្ធ័ផ្សេងទៀត) សំរាប់ការតវ៉ាគ្រប់គ្រាន់ដើម្បីបង្ហាញបញ្ហាឱ្យបានច្បាស់លាស់។

៣. នៅពេលដែលភាគីតវ៉ាច្រើនជាងមួយ សំណូមឱ្យចាត់តាំងសាលាក្តីពាក់ព័ន្ធដល់រឿងដូចគ្នាសាលាក្តីតែមួយអាចចាត់តាំងឡើងដោយបណ្តាភាគីពាក់ព័ន្ធនៅពេលដែលអាចធ្វើទៅបានដើម្បីដោះស្រាយបញ្ហាដោយគិតគូរដល់សិទ្ធិរៀងៗខ្លួន។ ៧

៤. នៅពេលដែលសាលាក្តីតែមួយត្រូវបានចាត់តាំងក្រោមកថាខ័ណ្ឌណា សាលាក្តីនោះត្រូវរៀបចំការពិនិត្យ និងបង្ហាញលទ្ធផលទៅអោយភាគីទាំងអស់នៃវិវាទតាមវិធីដែលសិទ្ធិដែលគេត្រូវបានទទួលអោយសាលាក្តីដោយឡែកពិនិត្យបញ្ហាតែមួយនេះត្រូវបានបន្ថយ។ បើសិនជាភាគីមួយក្នុងចំណោមបណ្តាភាគីវិវាទសំណូមពរអោយសាលាក្តីចេញរបាយការណ៍ដោយឡែកអំពីវិវាទ ទៅអោយបណ្តាភាគីពាក់ព័ន្ធក្នុងករណីដែលក្របខ័ណ្ឌពេលវេលាអនុញ្ញាតអោយ។ ការស្នើសុំជាលាយល័ក្ខអក្សរដោយបណ្តាភាគីវិវាទត្រូវអាចរកបានដោយបណ្តាភាគីផ្សេងទៀត ហើយភាគីនីមួយៗនៃវិវាទមានសិទ្ធិមានវត្តមាននៅពេលភាគីណាមួយនៃភាគីផ្សេងទៀតនៃវិវាទដូចគ្នាបង្ហាញទស្សនៈរបស់ខ្លួនទៅអោយសាលាក្តី។

៥. នៅពេលដែលសាលាក្តីច្រើនជាងមួយត្រូវបានចាត់តាំងក្រោមកថាខ័ណ្ឌទី៣ ដើម្បីពិនិត្យបញ្ហាដូចគ្នាក្នុងកំរិតមួយជាអតិបរិមាដែលអាចធ្វើទៅបាន បណ្តាភាគីពាក់ព័ន្ធត្រូវចាត់តាំងអាជ្ញាកណ្តាលដូចគ្នាដើម្បីបំរើសាលាក្តីដោយឡែកនីមួយៗ ហើយកាលវិភាគនៃទំរង់ការរបស់សាលាក្តីដោយឡែកនីមួយៗត្រូវតែស៊ីចង្វាក់គ្នា។

## ប្រការ ៧
## សមាសភាពនៃសាលាក្តី

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬបណ្តាភាគីនៃវិវាទឯកភាព សាលាក្តីត្រូវមានសមាជិកចំនួន ៣ រូប។

២. ភាគីតវ៉ាត្រូវចាត់តាំងអាជ្ញាកណ្តាលទៅសាលាក្តីស្របតាមប្រការ ៦ ក្នុងរយៈពេល ២០ថ្ងៃ ពីការទទួលសំណូមពរឱ្យ ចាត់តាំងសាលាក្តីស្របតាមប្រការ ៦។ ភាគីត្រូវបានតវ៉ាត្រូវចាត់តាំងអាជ្ញាកណ្តាលទៅសាលាក្តីស្របតាមប្រការ ៦ ក្នុងរយៈពេល ៣០ថ្ងៃ ពីការទទួលសំណូមពរអោយចាត់តាំងសាលាក្តីស្របតាមប្រការ ៦។ បើភាគីណាមួយនៃវិវាទខកខានមិនបានចាត់តាំងអាជ្ញាកណ្តាលក្នុងរយៈពេលនោះ អាជ្ញាកណ្តាលដែលចាត់តាំងដោយភាគីផ្សេងទៀតនៃវិវាទត្រូវធ្វើជាអាជ្ញាកណ្តាលតែមួយនៃសាលាក្តី។

៣. នៅពេលដែលភាគីតវ៉ា និងភាគីត្រូវបានតវ៉ាបានចាត់តាំងអាជ្ញាកណ្តាលរៀងៗខ្លួនហើយស្របតាមកថាខ័ណ្ឌ ២ បណ្តាភាគីពាក់ព័ន្ធត្រូវខិតខំឯកភាពគ្នាលើអាជ្ញាកណ្តាលបន្ថែមដែលត្រូវធ្វើជាប្រធាន។ បើបណ្តាភាគីពាក់ព័ន្ធមិនអាច

៤. នៅពេលដែលសាលាក្ដីតែមួយត្រូវបានចាត់តាំងក្រោមកថាខ័ណ្ឌណា សាលាក្ដីនោះត្រូវរៀបចំការពិនិត្យ និងបង្ហាញលទ្ធផលទៅអោយភាគីទាំងអស់នៃវិវាទតាមវិធីដែលសិទ្ធិដែលគេត្រូវបានទទួលអោយសាលាក្ដីដោយឡែកពិនិត្យបញ្ហាតែមួយនេះត្រូវបានបន្ថយ ។ បើសិនជាភាគីមួយក្នុងចំណោមបណ្ដាភាគីវិវាទសំណូមពរអោយសាលាក្ដីចេញរបាយការណ៍ដោយឡែកអំពីវិវាទ ទៅអោយបណ្ដាភាគីពាក់ព័ន្ធក្នុងករណីដែលក្របខ័ណ្ឌពេលវេលាអនុញ្ញាតអោយ ។ ការស្នើសុំជាលាយល័ក្ខអក្សរដោយបណ្ដាភាគីវិវាទត្រូវអាចរកបានដោយបណ្ដាភាគីផ្សេងទៀត ហើយភាគីនីមួយៗនៃវិវាទមានសិទ្ធិមានវត្តមាននៅពេលភាគីណាមួយនៃភាគីផ្សេងទៀតនៃវិវាទដូចគ្នាបង្ហាញទស្សនៈរបស់ខ្លួនទៅអោយសាលាក្ដី ។

៥. នៅពេលដែលសាលាក្ដីច្រើនជាងមួយត្រូវបានចាត់តាំងក្រោមកថាខ័ណ្ឌទី៣ ដើម្បីពិនិត្យបញ្ហាដូចគ្នាក្នុងកំរិតមួយជាអតិបរិមាដែលអាចធ្វើទៅបាន បណ្ដាភាគីពាក់ព័ន្ធត្រូវចាត់តាំងអាជ្ញាកណ្ដាលដូចគ្នាដើម្បីបំរើសាលាក្ដីដោយឡែកនីមួយៗ ហើយកាលវិភាគនៃទំរង់ការរបស់សាលាក្ដីដោយឡែកនីមួយៗត្រូវតែស៊ីចង្វាក់គ្នា ។

## ប្រការ ៧
## សមាសភាពនៃសាលាក្ដី

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬបណ្ដាភាគីនៃវិវាទឯកភាព សាលាក្ដីត្រូវមានសមាជិកចំនួន ៣ រូប ។

២. ភាគីតវ៉ាត្រូវចាត់តាំងអាជ្ញាកណ្ដាលទៅសាលាក្ដីស្របតាមប្រការ ៦ ក្នុងរយះពេល ២០ថ្ងៃ ពីការទទួលសំណូមពរឱ្យ ចាត់តាំងសាលាក្ដីស្របតាមប្រការ ៦។ ភាគីត្រូវបានតវ៉ាត្រូវចាត់តាំងអាជ្ញាកណ្ដាលទៅសាលាក្ដីស្របតាមប្រការ ៦ ក្នុងរយះពេល ៣០ថ្ងៃ ពីការទទួលសំណូមពរអោយចាត់តាំងសាលាក្ដីស្របតាមប្រការ ៦។ បើភាគីណាមួយនៃវិវាទខកខានមិនបានចាត់តាំងអាជ្ញាកណ្ដាលក្នុងរយះពេលនោះ អាជ្ញាកណ្ដាលដែលចាត់តាំងដោយភាគីផ្សេងទៀតនៃវិវាទត្រូវធ្វើជាអាជ្ញាកណ្ដាលតែមួយនៃសាលាក្ដី ។

៣. នៅពេលដែលភាគីតវ៉ា និងភាគីត្រូវបានតវ៉ាបានចាត់តាំងអាជ្ញាកណ្ដាលរៀង១ខ្លួនហើយស្របតាមកថាខ័ណ្ឌ ២ បណ្ដាភាគីពាក់ព័ន្ធត្រូវខិតខំឯកភាពគ្នាលើអាជ្ញាកណ្ដាលបន្ថែមដែលត្រូវធ្វើជាប្រធាន ។ បើបណ្ដាភាគីពាក់ព័ន្ធមិនអាច

## ប្រការ ៨
## មុខងាររបស់សាលាក្តី

១. មុខងាររបស់សាលាក្តី គឺការវាយតម្លៃដោយមិនលំអៀង នៃវិវាទរាប់បញ្ចូលទាំងការពិនិត្យដំណើរហេតុនៃករណី និងភាពអាចអនុវត្តបាន និងការអនុលោមតាមនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ។ នៅទីណាដែលសាលាក្តីសំរេចថាវិធានការមិនស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ សាលាក្តីត្រូវផ្តល់អនុសាសន៍ឱ្យភាគីត្រូវបានតវ៉ាធ្វើឱ្យវិធានការនោះស្របតាមបទបញ្ញត្តិទាំងនោះ។ បន្ថែមពីលើអនុសាសន៍របស់ខ្លួនសាលាក្តីអាចស្នើវិធីដែលភាគីត្រូវបានតវ៉ាអាចអនុវត្តអនុសាសន៍។ នៅក្នុងសេចក្តីសំរេចនិងអនុសាសន៍របស់ខ្លួន សាលាក្តីពុំអាចបន្ថែមឬបន្ថយសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

២. សាលាក្តីត្រូវមានឯកសារកំណត់សិទ្ធិ និងអំណាចដូចខាងក្រោមលើកលែងតែបណ្តាភាគីវិវាទឯកភាព ផ្សេងក្នុងរយៈពេល ២០ថ្ងៃ ក្រោយការបង្កើត ÷

"ពិនិត្យដោយផ្អែកលើបទបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បញ្ហាដែលបញ្ជូនទៅអោយសាលាក្តីនេះដោយ( ឈ្មោះភាគី ) ... និងធ្វើសេចក្តីសំរេចការកំណត់អនុសាសន៍ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ" សាលាក្តីត្រូវសរសេរបទបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលបានយោងដោយបណ្តាភាគីវិវាទ។

៣. សាលាក្តីដែលបានបង្កើតអនុលោមតាមប្រការខាងលើ ÷

ក- ត្រូវពិគ្រោះជាទៀងទាត់ជាមួយបណ្តាភាគីវិវាទ និងផ្តល់ឱកាសគ្រប់គ្រាន់សំរាប់ការរៀបចំដំណោះស្រាយមួយពេញចិត្តទៅវិញទៅមក

ខ- ត្រូវធ្វើការសំរេចស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងវិធាននៃច្បាប់អន្តរជាតិដែលអាចអនុវត្តបានរវាងបណ្តាភាគីវិវាទ

គ- ត្រូវកំណត់នៅក្នុងសេចក្តីសំរេចរបស់ខ្លួននូវលទ្ធផលនៃច្បាប់ និងដំណើរហេតុជាមួយនឹងមូលហេតុរបស់ វា

៤. សេចក្តីសំរេចនៃសាលាក្តី គឺជាសេចក្តីសំរេចស្ថាពរ និងចងបណ្តាភាគីវិវាទ។

៥. សាលាក្តីត្រូវធ្វើសេចក្តីសំរេចដោយឯកច្ឆន្ទ។ ក្នុងករណីដែលសាលាក្តីមិនអាចសំរេចដោយឯកច្ឆន្ទនោះអាចសំរេចដោយមតិភាគីច្រើន។

៦. សាលាក្តីត្រូវរៀបចំនីតិវិធីរបស់ខ្លួន ដែលពាក់ព័ន្ធដល់សិទ្ធិរបស់បណ្តាភាគីដែលត្រូវកាត់ និងពិភាក្សា។

## ប្រការ ៩
## ទម្រង់ការរបស់សាលាក្តី

១. សាលាក្តីត្រូវប្រជុំជាសម្ងាត់ បណ្តាភាគីវិវាទអាចមានវត្តមាននៅពេលប្រជុំតែកាលណាអញ្ជើញដោយសាលាក្តីឱ្យបង្ហាញខ្លួនចំពោះមុខខ្លួន។

២. ទីកន្លែងប្រជុំសំខាន់នៃសាលាក្តី ត្រូវតែសំរេចដោយការព្រមព្រៀងទៅវិញទៅមករវាងបណ្តាភាគីវិវាទ។ ការប្រជុំសំខាន់លើកទី១ ត្រូវធ្វើឡើងនៅទីក្រុងនៃភាគីត្រូវបានតវ៉ា ឬការប្រជុំសំខាន់លើកទី២ត្រូវធ្វើឡើងនៅទីក្រុងនៃភាគីតវ៉ា។

៣. ក្រោយការពិគ្រោះបណ្តាភាគីវិវាទ សាលាក្តីត្រូវកំណត់ឱ្យបានឆាប់បំផុតក្នុងរយៈពេល១៥ថ្ងៃក្រោយការបង្កើតសាលាក្តីនូវកាលវិភាគនៃរឿងក្តី។ ក្នុងការកំណត់កាលវិភាគរឿងក្តីសាលាក្តីត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់បណ្តាភាគីវិវាទដើម្បីរៀបចំឯកសារដាក់ជូនពិនិត្យរៀង១ខ្លួន។ សាលាក្តីគួរសំរេចពេលកំណត់ជាក់លាក់សំរាប់ការដាក់ឱ្យពិនិត្យជាលាយល័ក្ខអក្សរដោយបណ្តាភាគីវិវាទ ហើយគេត្រូវគោរពពេលកំណត់នេះ។

៤. ការពិភាក្សានៃសាលាក្តីនិងឯកសារដាក់ជូនពិនិត្យត្រូវទុកជាការសម្ងាត់។ គ្មានអ្វីនៅក្នុងប្រការនេះច្រានចោលបណ្តាភាគីវិវាទពីការបញ្ចេញអោយដឹងពីការថ្លែងអោយដឹងពីជំហររបស់ខ្លួន ឬឯកសារជូនពិនិត្យដល់សាធារណជន។ ភាគីវិវាទត្រូវចាត់ទុកជាការសម្ងាត់ពត៌មានដាក់ជូនដោយភាគីណាមួយពាក់ព័ន្ធទៅនឹងសាលាក្តីដែលភាគីដាក់ជូនពិនិត្យនោះចាត់ទុកជាការសម្ងាត់។ នៅទីណាដែលភាគីវិវាទដាក់ជូនច្បាប់សម្ងាត់នៃការដាក់ជូនពិនិត្យជាលាយល័ក្ខអក្សរទៅឱ្យសាលាក្តីដែលត្រូវតាមសំណូមពររបស់ភាគីពាក់ព័ន្ធផ្សេងទៀត ផ្តល់ផងដែរនូវសេចក្តីសង្ខេបមិនសម្ងាត់នៃពត៌មានដែលមាននៅក្នុងការដាក់ជូនពិនិត្យដែលអាចបញ្ចេញឱ្យសាធារណជនដឹង។

៥. វិធានការ និងនីតិវិធីពាក់ព័ន្ធដល់ទម្រង់ការចំពោះមុខសាលាក្តី ដូចចែងនៅក្នុងឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តលើកលែងតែសាលាក្តីសំរេចផ្សេងក្រោយពិគ្រោះបណ្តាភាគីវិវាទ ។

៦. របាយការណ៍សាលាក្តីត្រូវព្រាងដោយអវត្តមាននៃបណ្តាភាគីវិវាទ ដោយមានពត៌មាននិងការថ្លែងដែលបានផ្តល់ឱ្យ ។ ការពិភាក្សានៃសាលាក្តីត្រូវធ្វើដោយសម្ងាត់ ។ យោបល់បញ្ចេញដោយអាជ្ញាកណ្តាលនីមួយៗនៅក្នុងរបាយការណ៍ត្រូវតែអានាមិក ។

៧. ក្រោយការពិចារណាការដាក់ជូនពិនិត្យទឡ្ហីករណ៍ផ្ទាល់មាត់ និងពត៌មានណាមួយចំពោះមុខខ្លួន សាលាក្តីត្រូវចេញរបាយការណ៍ព្រាងទៅបណ្តាភាគីពាក់ព័ន្ធ រាប់បញ្ចូលទាំងផ្នែករៀបរាប់ទាក់ទងដល់ដំណើរហេតុនៃ វិវាទនិងទឡ្ហីករណ៍របស់ភាគីវិវាទ និងសេចក្តីសន្និដ្ឋាននិងសេចក្តីសំរេចរបស់សាលាក្តី ។ សាលាក្តីត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់បណ្តាភាគីពាក់ព័ន្ធដើម្បីពិនិត្យដោយហ្មត់ចត់ឡើងវិញនូវរបាយការណ៍ព្រាងទាំងស្រុងមុនការបញ្ចប់ និងត្រូវបញ្ចូលការពិភាក្សាការសង្កេតរបស់បណ្តាភាគីពាក់ព័ន្ធនៅក្នុងរបាយការណ៍ចុងក្រោយ ។

៨. សាលាក្តីត្រូវបញ្ចេញទៅអោយបណ្តាភាគីវិវាទ នូវរបាយការណ៍ចុងក្រោយរបស់ខ្លួនក្នុងរយៈពេល ១២០ ថ្ងៃពីកាលបរិច្ឆេទនៃការបង្កើត ។ ក្នុងករណីបន្ទាន់រាប់បញ្ចូលទាំងទំនិញងាយខូច សាលាក្តីត្រូវប្រុងប្រៀបចេញរបាយការណ៍ទៅឱ្យបណ្តាភាគីវិវាទក្នុងរយៈពេល ៦០ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្កើត ។ ពេលណាដែលសាលាក្តីគិតថាពុំអាចចេញរបាយការណ៍ចុងក្រោយក្នុងរយៈពេល ១២០ថ្ងៃ ឬក្នុងរយៈពេល ៦០ថ្ងៃ ក្នុងករណីបន្ទាន់ សាលាក្តីត្រូវជូនពត៌មានទៅបណ្តាភាគីពាក់ព័ន្ធជាលាយលក្ខអក្សរនូវមូលហេតុនៃការយឺតយូរ ជាមួយរយៈពេលប៉ាន់ស្មានដែលអាចចេញរបាយការណ៍របស់ខ្លួន។ ក្នុងករណីដែលរយៈពេលចាប់ពីការបង្កើត សាលាក្តីរហូតដល់ការបញ្ចេញរបាយការណ៍ទៅបណ្តាភាគីវិវាទលើសពី ១៨០ថ្ងៃ ។

៩. របាយការណ៍នៃសាលាក្តីត្រូវនៅជាឯកសារសាធារណៈក្នុងរយៈពេល១០ថ្ងៃក្រោយការបញ្ចេញទៅបណ្តាភាគីពាក់ព័ន្ធ ។ឃ

## ប្រការ ១០
## ភាគីទី ៣

១. ភាគីណាមួយដែលមានផលប្រយោជន៍ធំដុំក្នុងវិវាទនៅចំពោះមុខសាលាក្តី និងបានជូនពត៌មានពីការទាក់ទងនឹងផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅឱ្យបណ្តាភាគីវិវាទនេះនិងភាគីនៅសល់ (ខាងក្រោយនេះហៅថាភាគីទីពី) ត្រូវមានឱកាសដាក់ជូនពិនិត្យជាលាយលក្ខណ៍អក្សរទៅសាលាក្តី។ ការដាក់ជូនពិនិត្យនេះត្រូវផ្តល់ទៅឱ្យបណ្តាភាគីវិវាទ និង ត្រូវបង្ហាញឱ្យឃើញនៅក្នុងរបាយការណ៍នៃសាលាក្តី។

២. ភាគីទីពីត្រូវបានទទួលការដាក់អោយពិនិត្យនៃបណ្តាភាគីវិវាទចាប់ពីកិច្ចប្រជុំលើកទីមួយនៃសាលាក្តី។

៣. បើភាគីទីពីចាត់ទុកថា វិធានការដែលជាកម្មវត្ថុនៃទំរង់ការសាលាក្តីរួចទៅហើយនោះធ្វើអោយមោឃៈ ឬបន្ថយផលប្រយោជន៍របស់ខ្លួនក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ភាគីនោះអាចងាកទៅនីតិវិធីដោះស្រាយវិវាទធម្មតាក្រោមកិច្ចព្រមព្រៀងនេះ។

## ប្រការ ១១
## ការព្យួរ និងការបញ្ចប់នីតិវិធីការ

១. នៅទីណាដែលបណ្តាភាគីវិវាទឯកភាព សាលាក្តីអាចព្យួរការងាររបស់ខ្លួននៅពេលណាក៏បានសំរាប់រយៈពេលមិនលើសពី ១២ខែ ពីកាលបរិច្ឆេទនៃការឯកភាពនេះ។ តាមសំណូមពររបស់ភាគីណាមួយនៃវិវាទទំរង់ការអាជ្ញាកណ្តាលត្រូវចាប់ផ្តើមឡើងវិញក្រោយការព្យួរនេះ។ បើការងារនៃសាលាក្តីត្រូវបានព្យួរច្រើនជាង ១២ខែ អំណាចនៃការបង្កើតសាលាក្តីនឹងត្រូវអស់លើកលែងតែភាគីពាក់ព័ន្ធឯកភាពផ្សេងពីនេះ។

២. បណ្តាភាគីវិវាទអាចឯកភាពបញ្ចប់ទំរង់ការសាលាក្តី ដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះមុនការបញ្ចេញរបាយការណ៍ចុងក្រោយក្នុងករណីដែលដំណោះស្រាយពេញចិត្តទៅវិញទៅមកត្រូវបានរកឃើញ។

៣. មុនសាលាក្តីធ្វើសេចក្តីសំរេច សាលាក្តីអាចស្នើដល់បណ្តាភាគីវិវាទនៅតំណាក់កាលណាមួយនៃទំរង់ការវិវាទ ថាវិវាទបានដោះស្រាយដោយមេត្រីភាព។

## ប្រការ ១២

## **ការអនុវត្តន៍**

១. ភាគីត្រូវបានតវ៉ាត្រូវជូនដំណឹងភាគីតវ៉ានូវបំណងនៃការអនុវត្តអនុសាសន៍ និងសេចក្តីសំរេចនៃសាលាក្តី។

២. បើមានការលំបាកក្នុងការអនុវត្តន៍តាមអនុសាសន៍និងសេចក្តីសំរេចរបស់សាលាក្តីភ្លាមៗ ភាគីត្រូវបានតវ៉ាមានរយៈពេលសមស្របដើម្បីអនុវត្តតាម។ រយៈពេលសមស្របត្រូវកំណត់ដោយបណ្តាលភាគីវិវាទទាំងសងខាង ឬនៅទីណាដែលបណ្តាភាគីពាក់ពន្ធ័ខកខានមិនឯកភាពលើរយៈពេលសមរម្យក្នុងរយៈពេល៣០ថ្ងៃពីការចេញរបាយការណ៍ចុងក្រោយនៃសាលាក្តី ភាគីណាមួយនៃបណ្តាភាគីវិវាទអាចបញ្ជូនរឿងនេះទៅឱ្យសាលាក្តីបឋមដែលត្រូវនៅទីណាក៏ដោយដែលអាចធ្វើទៅបាន កំណត់រយៈពេលសមរម្យក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការបញ្ជូនរឿងក្តីទៅឱ្យ និងក្រោយការពិគ្រោះជាមួយបណ្តាភាគីពាក់ព័ន្ធ។ ពេលណាដែលសាលាក្តីគិតថាខ្លួនពុំអាចផ្តល់របាយការណ៍នៅក្នុងរយៈពេលកំណត់នោះសាលាក្តីត្រូវជូនពត៌មានទៅបណ្តាភាគីពាក់ព័ន្ធជាលាយល័ក្ខអក្សរនូវមូលហេតុនៃការពន្យារ និងត្រូវជូនពិនិត្យរបាយការណ៍របស់ខ្លួនមិនយឺតជាង ៤៥ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការបញ្ជូនរឿងក្តីទៅឱ្យ។

៣. នៅទីណាដែលមានការខ្វែងគំនិតគ្នាអំពីការមាន ឬភាពមិនប្រែប្រួលនៃវិធានការដែលបានចាត់ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងរយៈពេលសមរម្យដូចមានចែងក្នុងកថាខ័ណ្ឌ ២ ដើម្បីអនុវត្តតាមអនុសាសន៍នៃសាលាក្តីវិវាទនេះត្រូវបញ្ជូនទៅឱ្យសាលាក្តីដើមនៅទីណាដែលអាចធ្វើបាន។ សាលាក្តីត្រូវផ្តល់របាយការណ៍របស់ខ្លួនទៅឱ្យបណ្តាភាគីវិវាទក្នុងរយៈពេល ៦០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការបញ្ជូនរឿងក្តីទៅឱ្យ។ កាលណាសាលាក្តីគិតថាខ្លួនមិនអាចផ្តល់របាយការណ៍ក្នុង រយៈពេលនេះសាលាក្តីត្រូវជូនដំណឹងទៅបណ្តាភាគីពាក់ព័ន្ធជាលាយល័ក្ខអក្សរអំពីមូលហេតុនៃការពន្យារ និងត្រូវដាក់បាយការណ៍ខ្លួនមិនយឺតជាង ៧៥ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការបញ្ជូនរឿងក្តីទៅឱ្យ។

## ប្រការ ១៣

## ការសង និង ការព្យួរសម្បទាន ឬផលប្រយោជន៍

១. ការសង និងការព្យួរសម្បទាន ឬផលប្រយោជន៍ គឺជាវិធានការបណ្ដោះអាសន្នដែលអាចរកបានក្នុងករណីដែលអនុសាសន៍របស់សេចក្ដីសំរេចមិនបានអនុវត្តក្នុងរយៈពេលសមរម្យ។ ក៏ប៉ុន្តែទាំងការសងទាំងការព្យួរសម្បទាន ឬផលប្រយោជន៍ពុំមែនជាការប្រាថ្នាចង់បានដើម្បីការអនុវត្តន៍ពេញលេញនៃអនុសាសន៍ក្នុងទិសដៅធ្វើឱ្យវិធានការស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនោះឡើយ។ ការសងគឺធ្វើដោយស្ម័គ្រចិត្តនិងបើយល់ព្រមផ្ដល់ត្រូវស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

២. បើភាគីត្រូវបានតវ៉ា ខកខានមិនបានធ្វើអោយវិធានការដែលបានរកឃើញថាមិនសមស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្របតាមអនុសាសន៍នៃសាលាក្ដីក្នុងរយៈពេលសមរម្យដែលបានកំណត់អនុលោមទៅតាមកថាខ័ណ្ឌ ២ នៃប្រការ ១២ ភាគីនោះត្រូវចាប់ផ្ដើមចរចាជាមួយភាគីតវ៉ាបើមានសំណូមពរចរចាដើម្បីឈានដល់ការឯកភាពដោយពេញចិត្តទៅវិញទៅមកអំពីកាទូទាត់សំណងចាំបាច់ណាមួយ។

៣. បើគ្មានការព្រមព្រៀងពេញចិត្តទៅវិញទៅមក អំពីការសងត្រូវបានសំរេចក្នុងរយៈពេល ២០ថ្ងៃ ក្រោយសំណូមពររបស់ភាគីតវ៉ាឱ្យចាប់ផ្ដើមការចរចាអំពីការទូទាត់សង ភាគីតវ៉ាអាចសំណូមពរសាលាក្ដីដើម្បីកំណត់កំរិតសមស្របនៃការ ព្យួរសម្បទាន ឬផលប្រយោជន៍ដែលត្រូវផ្ដល់ទៅឱ្យភាគីដែលបានខកខានមិនបានធ្វើឱ្យវិធានការរកឃើញថាមិនស្របតាមកិច្ចព្រមព្រៀងក្រមខ័ណ្ឌសមស្របតាមអនុសាសន៍របស់សាលាក្ដី។ សាលាក្ដីត្រូវផ្ដល់របាយការណ៍ទៅឱ្យបណ្ដាភាគីវិវាទក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការបញ្ជូនរឿងក្ដីទៅឱ្យ។ កាលណាសាលាក្ដីគិតថាខ្លួនមិនអាចផ្ដល់ របាយការណ៍ក្នុងរយៈពេលនេះសាលាក្ដីត្រូវជូនពត៌មានទៅបណ្ដាភាគីពាក់ព័ន្ធជាលាយល័ក្ខអក្សរអំពីមូលហេតុនៃការពន្យារ និងត្រូវផ្ដល់របាយការណ៍មិនយឺតជាង ៤៥ថ្ងៃ ក្រោយកាលបរិច្ឆេតនៃការបញ្ជូនរឿងក្ដីទៅឱ្យ។ សម្បទាននិងផលប្រយោជន៍ មិនត្រូវព្យួរឡើយក្នុងរយៈពេលនៃទម្រង់ការអាជ្ញាកណ្ដាល។

៤. ការព្យួរសម្បទាន និងផលប្រយោជន៍ណាក់ដោយក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវតែកំណត់ព្រំដែនត្រឹមការព្យួរចំពោះភាគីដែលខកខានមិនបានធ្វើឱ្យវិធានការ ដែលបានរកឃើញថាមិនសមស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្រប

តាមអនុសាសន៍នៃសាលាក្តី ។ ភាគីនោះនិងបណ្តាភាគីដែលនៅសល់ត្រូវបានជូនដំណឹងពីការចាប់ផ្តើម ឬសេចក្តីលំអិតនៃការព្យួរនេះ ។

៥. ក្នុងការពិចារណាថាសម្បទាន ឬផលប្រយោជន៍ណាដែលត្រូវព្យួរ ៖

ក-ភាគីតវ៉ាគួរខិតខំជាបឋមព្យួរសម្បទាន ឬផលប្រយោជន៍ នៃផ្នែកឬបណ្តាផ្នែកដូចដែលបានប៉ះពាល់ដោយវិធានការទាំងនោះ ឬអ្វីផ្សេងទៀតដែលសាលាក្តីបានរកឃើញថា មិនសមស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬបានបណ្តាលអោយមានមោឃភាព ឬការបន្ថយ ។

ខ-ភាគីតវ៉ាអាចព្យួរសម្បទាន ឬផលប្រយោជន៍នៃផ្នែកផ្សេងទៀត បើគេគិតថាមិនងាយស្រួល ឬមិនមានប្រសិទ្ធិភាពក្នុងការព្យួរសម្បទាន ឬផលប្រយោជន៍នៃផ្នែកដូចគ្នា ។

៦. ការព្យួរសម្បទានឬផលប្រយោជន៍ត្រូវតែបណ្តោះអាសន្ន និងត្រូវតែអនុវត្តរហូតដល់ពេលដែលវិធានការដែលបានរកឃើញថាមិនសមស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវបំបាត់ចោលឬភាគីត្រូវអនុវត្តអនុសាសន៍របស់សាលាក្តីបានអនុវត្តរួចហើយ ឬដំណោះស្រាយពេញចិត្តទៅវិញទៅមកត្រូវបានសំរេច ។

## ប្រការ ១៥
## ភាសា

១. ទម្រង់ការទាំងអស់ស្របតាមកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាអង់គ្លេស ។

២. ឯកសារណាក៏ដោយដែលបានដាក់ជូនសំរាប់ការប្រើប្រាស់ក្នុងទម្រង់ការស្របតាមកិច្ចព្រមព្រៀងនេះត្រូវតែជាភាសាអង់គ្លេស ។ បើឯកសារដើមណាមួយមិនមែនជាភាសាអង់គ្លេស ភាគីដែលបានដាក់ជូនសំរាប់ប្រើប្រាស់ក្នុងទម្រង់ការស្របតាមកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការបកប្រែជាអង់គ្លេសនៃឯកសារនោះ ។ ៧

## ប្រការ ១៥
## ការចំណាយ

១. ភាគីនិមួយៗត្រូវទទួលខុសត្រូវថ្លៃចាត់តាំងអាជ្ញាកណ្តាល ចំណាយផ្ទាល់ខ្លួន និងថ្លៃចំណាយស្របច្បាប់ដទៃ ទៀត។

២. ថ្លៃប្រធានសាលាក្តី និងចំណាយផ្សេងទៀតពាក់ព័ន្ធដល់ការរៀបចំទម្រង់ការត្រូវទទួលខុសត្រូវស្មើភាគគ្នាដោយបណ្តាភាគីនៃវិវាទ។

## ប្រការ ១៦
## ការកែប្រែ

បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចកែប្រែតាមរយៈវិសោធនកម្មដោយការឯកភាពទៅវិញទៅមកជាលាយល័ក្ខអក្សរដោយបណ្តាភាគី។

## ប្រការ ១៧
## កន្លែងតម្កល់ទុក

សំរាប់អាស៊ាន កិច្ចព្រមព្រៀងនេះត្រូវរក្សាទុកដោយអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្តល់ច្បាប់ដោយមាន ការបញ្ជាក់មកពីប្រទេសសមាជិកអាស៊ាននីមួយៗ។

## ប្រការ ១៨
## ការចូលជាធរមានបញ្ញត្តិ

១. កិច្ចព្រមព្រៀងនេះចូលជាធរមាន នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ ។៧

២. បណ្ដាភាគីដែលកបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ ។

៣. នៅទីណាដែលភាគីពុំអាចបញ្ចប់នីតិវិធីក្នុងស្រុក  សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះនៅថ្ងៃ  ទី០១ ខែ មករា ឆ្នាំ ២០០៥  សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនេះក្រោមកិច្ចព្រមព្រៀងនេះត្រូវចាប់ផ្ដើមនៅកាលបរិច្ឆេទនៃការបញ្ចប់នីតិវិធីក្នុងស្រុកនេះ ។

៤.  នៅពេលបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ   ភាគីត្រូវជូនដំណឹងដល់បណ្ដាភាគីជាលាយល័ក្ខអក្សរ ។  ជាភស្តុតាង និងដោយមានការអនុញ្ញាតិត្រឹមត្រូវពីរាជរដ្ឋាភិបាលរៀងខ្លួនអ្នកចុះហត្ថលេខាខាងក្រោមនេះបានចុះហត្ថលេខាកិច្ចព្រមព្រៀងស្ដីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

**ធ្វើនៅ**វៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ ជាពីរច្បាប់ជាភាសាអង់គ្លេស ។

## វិធាន និង នីតិវិធីសំរាប់ទម្រង់ការអាជ្ញាកណ្តាល

១. មុនកិច្ចប្រជុំសំខាន់លើកទី១នៃសាលាក្តីជាមួយបណ្តាភាគីវិវាទ បណ្តាភាគីពាក់ព័ន្ធត្រូវបញ្ជូនទៅឱ្យសាលាក្តីនូវការដាក់អោយពិនិត្យជាលាយល័ក្ខអក្សរ ដែលប្រាប់ដំណើរហេតុនៃករណី និងទឡ្ហីករណ៍ ។

២. ភាគីតវ៉ាត្រូវបញ្ជូនសំណុំឯកសារលើកទី១ មុនការបញ្ជូនសំណុំឯកសារលើកទី១របស់ភាគីត្រូវបានតវ៉ាលើកលែងតែសាលាក្តីសំរេចថាបណ្តាភាគីពាក់ព័ន្ធ ត្រូវដាក់សំណុំឯកសារដំណាលគ្នាក្នុងការកំណត់កាលវិភាគដូចចែងក្នុងកថាខ័ណ្ឌ ៣ នៃប្រការ ៩ និងក្រោយការពិគ្រោះជាមួយបណ្តាភាគីពាក់ព័ន្ធ។ កាលណាមានការសម្រុះសម្រួលតាមលំដាប់សំរាប់ការដាក់សំណុំឯកសារលើកទី ១ សាលាក្តីត្រូវកំណត់រយៈពេលម៉ឺងម៉ាត់សំរាប់ទទួលឯកសារពីភាគីត្រូវបានតវ៉ា។ សំណុំឯកសារបន្តបន្ទាប់ត្រូវដាក់ដំណាលគ្នា។

៣. នៅកិច្ចប្រជុំសំខាន់លើកទី១ ជាមួយបណ្តាភាគីវិវាទសាលាក្តីត្រូវសុំអោយភាគីតវ៉ាបង្ហាញសុំណុំឯកសាររបស់ខ្លួន។ ក្រោយមកទៀតនិងនៅកិច្ចប្រជុំដដែលនេះភាគីត្រូវបានតវ៉ាត្រូវបង្ហាញសំណុំឯកសាររបស់ខ្លួន។

៤. ការឆ្លើយតបជាផ្លូវការត្រូវធ្វើនៅកិច្ចប្រជុំសំខាន់លើកទី២នៃសាលាក្តី។ ភាគីត្រូវបានតវ៉ាមានសិទ្ធិបង្ហាញ ឯកសារមុនគេ និងបន្ទាប់មកទៀតគឺភាគីតវ៉ា។ បណ្តាភាគីវិវាទត្រូវដាក់ការឆ្លើយតបជាលាយល័ក្ខអក្សរនៅសាលាក្តីមុនកិច្ចប្រជុំ។

៥. សាលាក្តីអាចនៅមានពេលណាក៏ដោយ សួរបណ្តាភាគីវិវាទដើម្បីសុំការពន្យល់នៅក្នុងកិច្ចប្រជុំជាមួយបណ្តាភាគីពាក់ព័ន្ធ ឬជាលាយលក្ខ័អក្សរ។

៦. ច្បាប់ជាលាយលក្ខ័អក្សរនៃការថ្លែងដោយផ្ទាល់មាត់នៃបណ្តាភាគីវិវាទ ត្រូវអាចរកបានដោយសាលាក្តី។

៧. ជាប្រយោជន៍ដល់តម្លាភាព ការបង្ហាញឯកសារ ការឆ្លើយតប និង ការថ្លែងដូចមានចែងក្នុងកថាខ័ណ្ឌ ២ ដល់ ៦ ត្រូវធ្វើដោយមានវត្តមាននៃបណ្តាភាគីវិវាទ។ ៉ាងទៀតសំណុំឯកសារនៃភាគីមួយៗរាប់បញ្ចូលទាំងយោបល់លើ៧

របាយការណ៍ព្រាងច្បាប់សាយលក្ខ័អក្សរនៃការថ្លែងផ្ទាល់មាត់ និងចម្លើយទៅនឹងសំណួរលើកឡើងដោយសាលាក្តីត្រូវតែអាចរកបានដោយភាគីផ្សេងទៀត ។ មិនត្រូវមានការទាក់ទងដែលលំអៀងទៅម្ខាងជាមួយសាលាក្តីអំពីរឿងក្តីដែលកំពុងពិចារណា ។

៨. សាលាក្តីអាចសុំយោបល់អ្នកជំនាញដើម្បីបានទទួលមតិលើទិដ្ឋភាពខ្លះនៃរឿងក្តី ។ ចំពោះបញ្ហាដែលស្របតាមការពិតអំពីទិដ្ឋភាពវិទ្យាសាស្ត្រ និងទិដ្ឋភាពបច្ចេកទេសផ្សេងទៀតលើកឡើងដោយភាគី ឬបណ្តាភាគី សាលាក្តីអាចសុំរបាយការណ៍ផ្តល់យោបល់ជាលាយលក្ខ័អក្សរពីអ្នកជំនាញ ឬបណ្តាអ្នកជំនាញ ។ សាលាក្តីអាច តាមសំណូមពររបស់ភាគី ឬបណ្តាភាគីវិវាទ ឬតាមឆន្ទៈផ្ទាល់ខ្លួនជ្រើសរើសដោយការពិគ្រោះជាមួយបណ្តាភាគីវិវាទ អ្នកជំនាញវិទ្យាសាស្ត្រ ឬអ្នកបច្ចេកទេសដែលអាចជួយសាលាក្តីក្នុងទំរង់ការរបស់ខ្លួន ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតលើការសំរេចណាមួយដោយសាលាក្តី ។